ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១២ លេខ ១ | មករា - មីនា ឆ្នាំ២០០៨ | តម្លៃ ១.៥០០៛


# របាយការណ៍សង្ខេបអំពីស្ថាប័នគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា

**លោក ច័ន្ទ សុផល ពិនិត្យពីបទប្បញ្ញត្តិ និងស្ថាប័នគ្រប់គ្រងចំណាកស្រុកពលករចេញពីកម្ពុជា និងគូសបញ្ជាក់ពីបញ្ហាសេដ្ឋកិច្ច-នយោបាយធំៗ ដែលរារាំងការកសាងប្រព័ន្ធល្អមួយសំរាប់គ្រប់គ្រងចំណាកស្រុកពលករ ព្រមទាំងលើកឡើងនូវ ដំណោះស្រាយមួយចំនួន ។***



*កម្មករចំណាកស្រុកកម្ពុជា ជួសជុលសំណាញ់មុនពេលចុះនេសាទ ។ ក្នុងមួយឆ្នាំៗ កម្មករប្រមាណ 180.000 នាក់ ចូលទៅក្នុងទឹកដីថៃខុសច្បាប់ ។*

ពាក់ព័ន្ធនឹងស្ថាប័ន គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា ប្រទេសកម្ពុជា នៅមានបទពិសោធន៍តិចជាងប្រទេសដទៃទៀត ។ ពលករភាគច្រើន ធ្វើដំណើរតាមមធ្យោបាយមិនផ្លូវការ រឺខុសច្បាប់ រីឯមធ្យោបាយស្របច្បាប់វិញ ទើបនឹងមានអនុវត្តក្នុងពេលថ្មីៗ ហើយត្រូវចំណាយអស់ច្រើន និងស្មុគស្មាញ ។ ស្ថាប័នរដ្ឋនានា នឹងត្រូវប្រឈមបញ្ហាកាន់តែច្រើន ចំពោះការគ្រប់គ្រងចំណាកស្រុកចេញរបស់ពលករដែលរំពឹងថានឹងកើនឡើង ដោយសារកត្តាទាំងខាងក្នុង និងខាងក្រៅ ។ ការធ្វើចំណាកស្រុក ទំនងជានឹងកើនឡើង ដោយសារការបង្កើតការងារក្នុងស្រុក មានល្បឿនយឺតជាង កំណើនពលករប្រចាំឆ្នាំ ដែលមានប្រហែល ៣០០.០០០នាក់ ។ ប្រាក់បៀវត្សរ៍ខ្ពស់ជាង និងតំរូវការពលករនៅប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង សិង្ហបុរី និងជប៉ុន គឺជាកត្តាទាក់ទាញពីខាងក្រៅ ។

ទោះជាយើងពេញចិត្តនឹងការបង្កើតឱកាសការងារ និងអភិវឌ្ឍន៍នៅក្នុងប្រទេសជាងក្តី ក៏យើងគួរមាន ប្រព័ន្ធគ្រប់គ្រង គោលនយោបាយ នឹងក្របខ័ណ្ឌច្បាប់ដ៏ល្អ សំរាប់គ្រប់គ្រងចំណាកស្រុកពលករដែរ ពីព្រោះចំណាកស្រុកអាចផ្តល់ ឱកាសការងារ និងចំណូលចាំបាច់សំរាប់រយៈពេលខ្លី និងមធ្យម ។ មិនតែប៉ុណ្ណោះ វាក៏អាចជួយកាត់បន្ថយភាពក្រីក្រផងដែរ ។ ប្រាក់ផ្ញើមកផ្ទះ មានតួលេខប៉ាន់ស្មានប្រហែល ២០០លានដុល្លារ រឺ ៣,២៣% នៃផសស ឆ្នាំ២០០៥ ហើយយើងរំពឹងថា អាចកើនឡើងរហូតដល់ ៥០០លានដុល្លារ បើសិនមានការគ្រប់គ្រងចំណាកស្រុកពលករបានប្រសើរជាងមុន ។

នៅឆ្នាំ២០០៥ ប្រទេសថៃបានបញ្ជូនពលករចំណាកស្រុកចេញ ១៦០.០០០នាក់ និងទទួលបានប្រាក់ផ្ញើមកផ្ទះ ១,២ពាន់លានដុល្លារ រីឯវៀតណាមបានបញ្ជូលពលករ ប្រហែល ៤០០.០០០នាក់ និងទទួលបានប្រាក់ផ្ញើមកផ្ទះ ប្រមាណ ៤ពាន់លានដុល្លារ យោងតាមសូចនាករអភិវឌ្ឍន៍

* ច័ន្ទ សុផល ជាអ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ ។ អត្ថបទនេះជាសង្ខេបនៃសេចក្តីព្រាងរបាយការណ៍ដែលវិទ្យាស្ថាន CDRI កំពុងសរសេរដោយមានការឧបត្ថម្ភថវិកា ដោយអង្គការពលកម្មអន្តរជាតិ (ILO) និងសហការជិតស្និតជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ យោបល់ ឬកំហុសដោយអចេតនា គឺជារបស់អ្នកនិពន្ធ និងមិនមែនជារបស់ CDRI ឬអង្គការ ILO ទេ ។

## មាតិកា


របាយការណ៍សង្ខេបអំពីស្ថាប័នគោលនយោបាយ ........ ១
ការគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា ........ ៦
ការទិញលក់ដីធ្លី និងបញ្ហា ផុសឡើងក្រោយពេលចាប់ផ្តើមចុះបញ្ជីដីធ្លី ........ ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៥
— ស្ថានភាពក្នុងប្រទេស ........ ១៨
— សន្ទស្សន៍សេដ្ឋកិច្ច ........ ២១
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........ ២៤

ពិភពលោក (World.Development.Indicators) ឆ្នាំ២០០៧ ផ្សព្វផ្សាយដោយធនាគារពិភពលោក។ ប្រទេសហ្វីលីពីន បានទទួលប្រាក់ផ្ញើមកផ្ទះ ១៣,៥ពាន់លានដុល្លារ (១៣,៧%នៃ ផសស) ហើយបង់ក្លាដេស បានទទួល ៤,២ពាន់លានដុល្លារ (៧%) ។ ការសិក្សារបស់មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍកសិកម្ម និងធនាគារអភិវឌ្ឍន៍ទ្វីបអាមេរិក (IFAD 2007) រកឃើញថា ពលករចំណាកស្រុកនៅលើពិភពលោកមាន ១៥០លាននាក់ ដែលបានផ្ញើប្រាក់មកផ្ទះ ៣០០ពាន់លានដុល្លារនៅឆ្នាំ២០០៦ គឺលើសពីជំនួយអភិវឌ្ឍន៍ និងវិនិយោគផ្ទាល់ពីបរទេសទៅទៀត ។

## ចំណាកស្រុកចេញពីកម្ពុជាតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ និងប្រាក់ផ្ញើមកផ្ទះ

ពលករចំណាកស្រុកចេញពីកម្ពុជាមានពីរប្រភេទធំៗ គឺ ប្រភេទស្របច្បាប់ និងមិនស្របច្បាប់ ។ យោងតាមស្ថិតិរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ពីឆ្នាំ១៩៩៨ ដល់ចុងឆ្នាំ២០០៧ មានពលករ ១០.៥៣២នាក់ ត្រូវបានបញ្ជូនជាផ្លូវការទៅម៉ាឡេស៊ី ៣៩៨៤នាក់ ទៅកូរ៉េខាងត្បូង និង ៦១១៤នាក់ ទៅថៃ (សរុប ២០.៦៣០នាក់) ។ ម្យ៉ាងទៀត មានពលករកម្ពុជាប្រហែល ១៨០.០០០នាក់ កំពុងធ្វើការនៅថៃ (IOM 2006) ក្នុងនេះ ១១០.០០០នាក់ បានទទួលលិខិតអនុញ្ញាតឱ្យធ្វើការចេញដោយរដ្ឋាភិបាលថៃនៅឆ្នាំ២០០៤ និងប្រហែល ៥០.០០០នាក់ បានទទួលលិខិតបញ្ជាក់ពីអត្តសញ្ញាណ (CI) ចេញដោយរដ្ឋាភិបាលកម្ពុជាតាមរយៈក្រុមការងារអន្តរក្រសួងដឹកនាំដោយក្រសួងការងារ ។

ពលករទៅម៉ាឡេស៊ីភាគច្រើនជាស្ត្រី ទៅធ្វើជាអ្នកបំរើ រឺអ្នកធ្វើការងារផ្ទះ រីឯពលករទៅកូរ៉េភាគច្រើនជាបុរស ។ ទោះបីប្រទេសថៃធ្លាប់បានទទួលពលករចំណាកស្រុកពីកម្ពុជាតាំងពីឆ្នាំ១៩៩៤ ប៉ុន្តែពលករភាគច្រើនគ្មានឯកសារបញ្ជាក់អ្វីទេ រឺក៏ជាពលករមិនស្របច្បាប់ ។ ការបញ្ជូនពលករចេញជាផ្លូវការ ទើបចាប់ផ្តើមក្នុងឆ្នាំ២០០៦ បន្ទាប់ពីមានអនុស្សរណៈព្រមព្រៀង (MOU) រវាងថៃ និងកម្ពុជា នៅខែឧសភា ឆ្នាំ២០០៣ ។ ពលករចំណាកស្រុកកម្ពុជា ទទួលបានតែការងារណាដែលមានលក្ខណៈគ្រោះថ្នាក់ ពិបាក និងគ្រោះថ្នាក់ជាពិសេស ខាងនេសាទ សំណង់ និងកសិកម្ម ។

## បទប្បញ្ញត្តិច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងចំណាកស្រុកពលករ

### *កង្វះក្របខ័ណ្ឌច្បាប់*

ដោយចំណាកស្រុកពលករចេញពីកម្ពុជា ជារឿងមួយថ្មី ហេតុនេះកម្ពុជាត្រូវជួបបញ្ហាប្រឈមក្នុងការបង្កើតគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ សំរាប់គ្រប់គ្រងចំណាកស្រុកពលករចេញ ។ នៅឆ្នាំ១៩៩៥ អនុក្រឹត្យលេខ៥៧ ស្តីពីការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ត្រូវបានអនុម័ត ។ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា[1] នាពេលនោះ ជាអ្នកតាក់តែងសេចក្តីព្រាងអនុក្រឹត្យ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស ។ អនុក្រឹត្យ បានទទួលស្គាល់ពីកង្វះខាតឱកាសការងារក្នុងស្រុក និងបញ្ជាក់ពីគោលដៅកែលំអកំរិតជីវភាពរបស់ប្រជាជនតាមរយៈការរកចំណូល និងទទួលបានជំនាញពីការងារក្រៅស្រុក ។ អនុក្រឹត្យកំណត់ឱ្យក្រសួងទទួលបន្ទុក (ពេលនោះ គឺក្រសួងការងារ) ធ្វើជាអ្នកផ្តល់ធនធានមនុស្ស ហើយក្រុមហ៊ុន រឺទីភ្នាក់ងារជ្រើសរើសពលករ ជាភាគីទទួលយកពលករ ។ ក្រៅពីអនុក្រឹត្យលេខ៥៧ នៅមានប្រកាសលេខ ១០៨ នៅខែឧសភា ឆ្នាំ២០០៦ ស្តីពីការអប់រំអំពីជំងឺអេដស៍ ចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារសំរាប់ពលករកម្ពុជា ធ្វើការនៅក្រៅស្រុក ព្រមទាំងអនុក្រឹត្យលេខ៧០ នៅខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាល ហត្ថពលកម្ម និងបញ្ជូនពលករទៅបរទេស (MTOSB) ។

អ្នកឆ្លើយសំភាសន៍ជាច្រើននាក់លើកឡើងថា កម្ពុជាខ្វះគោលនយោបាយទេសន្តប្រវេសន៍ រឺច្បាប់ជាក់លាក់សំរាប់ចំណាកស្រុក ។ នៅក្នុងគំនិតពួកគេ អនុក្រឹត្យលេខ ៥៧ (ឯកសារច្បាប់ជាធរមានតែមួយគត់ក្រៅពីប្រកាស) មានអាយុកាលយូរពេកហើយ និងគួរតែពិនិត្យកែសំរួលឡើងវិញ ។ ច្បាប់ការងាររបស់កម្ពុជា មិនអាចយកទៅអនុវត្តនៅប្រទេសទទួលយកពលករបានទេ ជាពិសេសទាក់ទិននឹងចំណាកស្រុកពលករ ។

### *កង្វះខាតក្នុងស្ថាប័នរដ្ឋ*

មានទស្សនៈថា គួរមានស្ថាប័នជំនាញដោយឡែកមួយទទួលខុសត្រូវគ្រប់គ្រងចំណាកស្រុកពលករ ។ អាចសមរម្យដែរ បើក្រសួងការងារបង្កើតការិយាល័យ រឺនាយកដ្ឋានមួយដោយឡែក អោយទទួលបន្ទុកជាពិសេសលើចំណាកស្រុកពលករ ។ អ្នកឆ្លើយសំភាសន៍ទាំងអស់ មានមតិឯកភាពគ្នាថា ត្រូវតែបង្កើនចំនួនបុគ្គលិកមានសមត្ថភាព ដើម្បីគ្រប់គ្រងបញ្ហាចំណាកស្រុកពលករដ៏ស្រួចស្រាវនេះ ។ ថវិកាផ្តល់ពីរដ្ឋាភិបាល ក៏អាចត្រូវបង្កើនដែរ ដើម្បីទាក់ទាញមន្ត្រីអ្នកមានសមត្ថភាពសមស្រប ។ ប៉ុន្តែ ក៏គួរមានវិធីសំរាប់អោយការិយាល័យ រឺនាយកដ្ឋាននេះ ទទួលបានថវិកាពីការងារចំណាកស្រុកពលករ ពីព្រោះសកម្មភាពនេះជួយផ្តល់ប្រាក់រាប់រយលានដុល្លារមកក្នុងប្រទេស ។

ដោយសារចំណាកស្រុកពលករពាក់ព័ន្ធនឹងក្រសួងជាច្រើន ហេតុនេះក៏មានការបង្កើតក្រុមការងារអន្តរក្រសួង គ្រប់គ្រងអន្តោប្រវេសន៍ (IMTM) មួយឡើងនាពេលថ្មីៗនេះ ដែលមានសហប្រធានជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងការងារ ។ គំនិតផ្តួចផ្តើមនេះបានផុសឡើងបន្ទាប់ពីមានការតស៊ូមតិបានជោគជ័យរបស់ មូលនិធិអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិដើម្បីស្ត្រី (UNIFEM) ដែលព្យាយាមលើកកំពស់សិទ្ធិរបស់ពលករស្ត្រីចំណាកស្រុក ។ ក្រុមការងារ IMTM មានសមាជិកមកពីក្រសួងសំខាន់ៗ ប៉ុន្តែទើបជួបប្រជុំបាន ២លើកប៉ុណ្ណោះ តាំងពីពេលកកើតឡើង នៅខែតុលា ឆ្នាំ២០០៦ មក ។ ក្រុមការងារនេះនៅថ្មីថ្មោង និងមានការងារជំរុញដោយធនធានបានពី UNIFEM ។ វាជាវេទិកាមួយសំរាប់ឱ្យស្ថាប័នរដ្ឋនានាជួបពិភាក្សាពីបញ្ហាចំណាកស្រុកពលករ និងស្វែងរកការមូលមតិគ្នាមុនពេលទៅជួបចរចារជាមួយប្រទេសជាភាគីទទួលយកពលករ និងមុនពេលតាក់តែងសេចក្តីព្រាងគោលនយោបាយ សំរាប់គ្រប់គ្រងចំណាកស្រុកពលករ ។ គេរំពឹងថា ក្រុមការងារ IMTM នឹងកសាងបាននូវគោលនយោបាយ និងបទប្បញ្ញត្តិដ៏ចាំបាច់នានា ប៉ុន្តែនៅមិនទាន់ដឹងទេថា តើនឹងមានដំណើរការបានសក្តិសិទ្ធិប៉ុណ្ណា ។

### *កង្វះខាតស្ថាប័នឯកជន*

អនុក្រឹត្យលេខ៥៧ បានកំណត់ចំបញ្ហាគ្មានការងារធ្វើ និងបញ្ហាមានការងារមិនគ្រប់គ្រាន់ ព្រមទាំងបង្ហាញពីផលចំណេញ បានមកពីចំណាកស្រុកពលករ ក្នុងការលើកកំពស់កំរិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែមានទិដ្ឋភាពមួយចំនួន បង្ហាញថា គោលបំណងអនុក្រឹត្យ និងគោលនយោបាយមិនស៊ីចង្វាក់គ្នាទេ ដូចជា ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករដាក់

ប្រាក់តំកល់ច្រើន និងចេញសោហ៊ុយចំណាយជាមុន ។

ម្យ៉ាងទៀតគួរមានទីភ្នាក់ងារជ្រើសរើសពលករច្រើនគ្រប់គ្រាន់ ដើម្បីទទួលចាត់ចែងលើពលករចំណាកស្រុកប្រមាណ ២០០.០០០នាក់ (ទាំងស្របច្បាប់ និងខុសច្បាប់) បើសិនចង់ឱ្យពួកគេប្រើប្រាស់មធ្យោបាយស្របច្បាប់ទាំងអស់គ្នា ។ ទាំងស្ថាប័នរដ្ឋ និងឯកជន ត្រូវតែមានច្រើនគ្រប់គ្រាន់និងរឹងមាំ ។ បច្ចុប្បន្ននេះ កំពុងមានកង្វះខាត ទាំងមន្ត្រីរដ្ឋដែលមានសមត្ថភាពដោះស្រាយបញ្ហាចំណាកស្រុកពលករ និងទីភ្នាក់ងារឯកជនសំរាប់ជ្រើសរើស បណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស ។

ពិតហើយ កង្វះខាតទីភ្នាក់ងារបញ្ជូនពលករទៅក្រៅស្រុក វាផុសចេញពីលក្ខខណ្ឌដ៏ខ្ពស់ដែលចែងក្នុងអនុក្រឹត្យ ។ ក្រុមហ៊ុនត្រូវដាក់ប្រាក់តំកល់ ១០០.០០០ដុល្លារ នៅឯក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងត្រូវបង់ចំណាយផ្សេងៗសំរាប់បញ្ជូនពលករ ។ លក្ខខណ្ឌនេះបានដាក់បន្ទុកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរមួយទៅលើក្រុមហ៊ុន ហើយជាមូលហេតុដែល ២៦ ក្រុមហ៊ុន ត្រូវបិទទ្វារក្នុងខែកក្កដា ឆ្នាំ២០០៦ នៅពេលមានការរឹតបណ្ដឹងឱ្យដាក់ប្រាក់ដំកល់ ហើយនៅសល់តែ ១២ក្រុមហ៊ុនប៉ុណ្ណោះ ដែលអាចបន្តដំណើរការ ។ នាពេលថ្មីៗ មាន ៤ក្រុមហ៊ុនទៀតបានកកើតឡើង ដូច្នេះសព្វថ្ងៃមាន សរុប ១៦ក្រុមហ៊ុន ដោយមិនរាប់បញ្ចូលនូវទីភ្នាក់ងារ ២ ទៀតដែលកំពុងព្យាយាមប្រែក្លាយខ្លួន ទៅជាអង្គការមិនមែនរដ្ឋាភិបាល (NGO) ។ យោងតាមប្រទេសដែលមានបទពិសោធន៍យូរអង្វែងក្នុងការនាំចេញពលករទៅបរទេស កម្ពុជានៅមានក្រុមហ៊ុនតិចហួសពេក ។ ជាក់ស្ដែងប្រទេសបង់ក្លាដេស មានប្រមាណ ៨០០ក្រុមហ៊ុន ធ្វើការជ្រើសរើស និង[2] បញ្ជូនពលករទៅបរទេស រីឯហ្វីលីពីន មានច្រើនជាង ១០០០ក្រុមហ៊ុន ។

### *ការពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល*

អង្គការមិនមែនរដ្ឋាភិបាល មានសកម្មភាពច្រើនពាក់ព័ន្ធនឹងបញ្ហាចំណាកស្រុក និងការជួញដូរមនុស្ស ។ បណ្ដាញ NGO ពាក់ព័ន្ធនឹងចំណាកស្រុក បានបង្កើតឡើងដោយមានការគាំទ្រពី UNIFEM និងការចូលរួមពីអង្គការចំនួន ៣០ ។ អង្គការទាំងនោះ ជួបប្រជុំរៀងរាល់ ២ខែម្ដង ដើម្បីអនុវត្តកម្មវិធីចំនួន ៥ ស្ដីពី ១) ការបំផុសចំណាប់អារម្មណ៍ និងការតស៊ូមតិ ២) ការស៊ើបអង្កេត ៣) ទិដ្ឋភាពច្បាប់ ៤) ការស្រាវជ្រាវ និងប្រមូលទិន្នន័យ និង ៥) ការកសាងសមត្ថភាព និងទំនាក់ទំនងសាធារណៈ ។ បណ្ដាញនេះ ដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារមួយ ដែលមានសមាសភាពមកពី[3] អង្គការសកម្មៗក្នុងបញ្ហាចំណាកស្រុកពលករ និងការជួញដូរមនុស្ស ។

## បញ្ហាសំខាន់ៗជាគន្លឹះនៅក្នុងការផ្ដល់សេវារដ្ឋបាលដល់ចំណាកស្រុកពលករ

### *តំលៃដំណើរការបញ្ជូនពលករទៅបរទេស*

ក្រោយពីរដ្ឋាភិបាលកម្ពុជា តែងតាំងឱ្យក្រុមប្រឹក្សាបណ្ដុះបណ្ដាលហត្ថពលកម្ម និងបញ្ជូនពលករទៅបរទេស (MTOSB) ជាអ្នកចាត់ចែងបណ្ដុះបណ្ដាល និងបញ្ជូនពលករដោយផ្ទាល់ តម្លៃបញ្ជូនពលករទៅប្រទេសកូរ៉េខាងត្បូង ធ្លាក់ពី ៣០០០ដុល្លារ ក្នុងពលករម្នាក់ មកត្រឹម ៨៩២ដុល្លារប៉ុណ្ណោះ នៅខែមករា ឆ្នាំ២០០៧ ។ នេះជាជោគជ័យដ៏ធំមួយ ដែលផ្ដល់អត្ថប្រយោជន៍ផ្ទាល់ដល់ពលករ ។ ចំណុចខុសគ្នាខ្លាំង គឺ កំរៃ និងចំណាយបញ្ជូនពលករ ដែលក្រុមហ៊ុនឯកជនទារយកពីពលករ ។ MTOSB មិនបានយកកំរៃទាំងពីរនេះ រឺក៏កំរៃសំរាប់ការអប់រំ/ណែនាំ និងពន្ធអ្វីទេ ហើយចាប់តាំងពីទទួលការងារនេះមក MTOSB បញ្ជូនពលករបានប្រហែល ៥០០នាក់ ។ នេះជាឧទាហរណ៍ជាក់ស្ដែងមួយដែល បញ្ជាក់ថា ការកាត់បន្ថយចំណាយក្នុងការបញ្ចូលពលករទៅបរទេស ពិតជាអាចធ្វើបាន ។

នាបច្ចុប្បន្ន តម្លៃបញ្ជូនពលករចំណាកស្រុកទៅធ្វើការនៅថៃ គឺ ៧០០ដុល្លារ ក្នុងនេះ ១០០ដុល្លារ ត្រូវបង់ដោយពលករម្នាក់ៗដែលដាក់ពាក្យសុំចំណាកស្រុក និង ៦០០ដុល្លារ (២០.០០០បាត) ត្រូវបង់ដោយនិយោជក រឺក្រុមហ៊ុនជ្រើសរើសបុគ្គលិក ហើយត្រូវកាត់ ២០០០បាត ក្នុងមួយខែ ចេញពីប្រាក់ខែពលករសំរាប់រយៈពេល ១០ខែ ។ ចំណាយនេះខ្ពស់ណាស់ បើធៀបនឹងប្រាក់ខែរបស់ពលករ ដែលជាមធ្យមទទួលបានប្រហែល ៦០០០បាត ហើយពលករត្រូវធ្វើការថែមម៉ោងដើម្បីអាចសន្សំប្រាក់បានច្រើនផ្ញើមកផ្ទះ ស្របតាមគោលបំណងដែលគេធ្វើចំណាកស្រុក ។ កំរៃមិនផ្លូវការសំរាប់ចំណាកស្រុកខុសច្បាប់ដែលបង់ឱ្យមេខ្យល់ គឺ ១០០ដុល្លារប៉ុណ្ណោះក្នុងពលករម្នាក់ ។ ម្យ៉ាងទៀត ពលករមិនបាច់រង់ចាំយូរទេ បើសិនប្រើមធ្យោបាយខុសច្បាប់ ។ នៅពេលជំរើសនេះអាចប្រើបាននៅឡើយ ពលករភាគច្រើន ប្រាកដជាជ្រើសយកមធ្យោបាយមិនស្របច្បាប់ដែលរហ័សដោយបង់ត្រឹម ១០០ដុល្លារ ជាជាងការបង់ប្រាក់ ៧០០ដុល្លារ និងត្រូវរង់ចាំពី ៣-៦ខែ ដើម្បីធ្វើចំណាកស្រុកទៅថៃ ។ ទោះបីអាចត្រូវសមត្ថកិច្ចចាប់ខ្លួន និងបញ្ជូនត្រឡប់មកវិញក្ដី ក៏ពលករចំណាកស្រុកភាគច្រើន នៅតែហ៊ានប្រថុយនឹងគ្រោះថ្នាក់ចូលទៅថៃដោយខុសច្បាប់ ។ ពលករដែលធ្លាប់ទៅថៃ តែងចូលទៅប្រទេសនោះម្ដងទៀតដោយខ្លួនឯង ហើយចំណាយតែប្រហែល ៥០ដុល្លារប៉ុណ្ណោះ សំរាប់ថ្លៃធ្វើដំណើរ ។

ព្រំដែនដ៏វែងបានធ្វើឱ្យអាជ្ញាធរកម្ពុជា និងថៃ លំបាកនឹងបញ្ឈប់ចំណាកស្រុកខុសច្បាប់ណាស់ ដូច្នេះការងារសំខាន់ គឺត្រូវសំរួលឱ្យចំណាកស្រុកស្របច្បាប់មានតំលៃថោកសមរម្យដែលពលករអាចចំណាយបាន ។ មានការស្នើឡើងថាតម្លៃ ៧០០ដុល្លារ គួរបញ្ចុះមកត្រឹម ៣០០ដុល្លារ ហើយរដ្ឋាភិបាលទាំងពីរ គួរជួយពន្លឿនដំណើរការបញ្ជូនពលករ ។ ក្នុងតំលៃសរុប ៧០០ដុល្លារនេះ ៤៨០ដុល្លារជាចំណាយនៅលើទឹកដីកម្ពុជា ។ លិខិតឆ្លងដែនគួរបញ្ចុះតម្លៃពី ១៥០ដុល្លារ មកត្រឹម ៥០ដុល្លារ ហើយចំណាយផ្សេងៗទៀតគួរបញ្ចុះពី ២២០ដុល្លារ មកត្រឹម ៤០ដុល្លារ ។ វិធីនេះ នឹងកាត់បន្ថយចំណាយនៅកម្ពុជាពី៤៨០ដុល្លារ មកត្រឹម ២០០ដុល្លារ ហើយក្រុមហ៊ុនក៏អាចរក្សាប្រាក់ចំណូលជាមធ្យម ៧០ដុល្លារ នេះបានដដែល ។

រដ្ឋាភិបាលថៃ គួរបញ្ចុះតម្លៃលិខិតអនុញ្ញាតការងារពី ១០៦ដុល្លារ (៣៥០០បាត) មកត្រឹម ៣០ដុល្លារ (១០០០បាត) និងតម្លៃទិដ្ឋាការពី ៥៩ដុល្លារ (២០០០បាត) មកត្រឹម ១៥ដុល្លារ (៥០០បាត) ។ ធ្វើដូច្នេះ តម្លៃសរុបនៅខាងថៃ នឹងថយចុះពី ២២០ដុល្លារ មកត្រឹម ១០០ដុល្លារ ។ យោងតាមក្រសួងការងារថៃ តម្លៃទិដ្ឋាការ នឹងកាត់បន្ថយមកត្រឹម ៥០០បាត ប៉ុន្តែមិនទាន់អនុវត្តទេនៅពេលសរសេរអត្ថបទនេះ[4] ។ ដូច្នេះការងារចំបងដែលរដ្ឋាភិបាលថៃអាចចូលរួមធ្វើ គឺការបញ្ចុះតម្លៃលិខិតអនុញ្ញាតការងារ ។ នៅពេលមានពលករច្រើនៗផ្លាស់ប្ដូរទៅប្រើមធ្យោបាយចំណាកស្រុកស្របច្បាប់វិញ រដ្ឋាភិបាលថៃនឹងទទួលបានចំណូលបន្ថែមទៀត ពីការចេញលិខិតអនុញ្ញាតការងារកាន់តែច្រើន ព្រមទាំងផលចំណេញជាច្រើនទៀត ។

### *តម្លៃលិខិតឆ្លងដែនកម្ពុជា*

ចាប់ពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ លិខិតឆ្លងដែនមានតម្លៃផ្លូវការ ១២០ដុល្លារ បន្ទាប់ពីបានតម្លើង ២០ដុល្លារទៀតសំរាប់បន្ថែមទិន្នន័យ

អេឡិចត្រូនិក[៥] ។ ប៉ុន្តែគេត្រូវបូកបន្ថែមតំលៃក្រៅផ្លូវការ ១៩ដុល្លារទៀត ដូច្នេះតម្លៃសរុបសំរាប់លិខិតឆ្លងដែនមួយ គឺ ១៣៩ដុល្លារ ។ តម្លៃនេះតំរូវឱ្យសាមុីជនរង់ចាំ ២ខែ ទើបទទួលបានលិខិតឆ្លងដែន ហើយបើសិនត្រូវការលិខិតឆ្លងដែនឆាប់ជាងនេះ ប្រជាពលរដ្ឋអាចសុំយកក្នុងរយៈពេល ១សប្តាហ៍ ប៉ុន្តែត្រូវបង់ ២២៤ដុល្លារ ។ រឿងនេះបង្ហាញថា ការចេញលិខិតឆ្លងដែនក្នុងរយៈពេលមួយសប្តាហ៍ អាចធ្វើទៅបាន ហើយការអូសបន្លាយពេល គឺដោយសារបន្ទុកការងារច្រើន រឺបញ្ហាផ្សេងទៀត ។

នៅប្រទេសវៀតណាម តម្លៃលិខិតឆ្លងដែនគឺ ១២ដុល្លារប៉ុណ្ណោះ ហើយរដ្ឋចេញឱ្យក្នុងរយៈពេល ៥ថ្ងៃ រីឯនៅប្រទេសថៃ និងប្រទេសឡាវ គឺ ៣០ដុល្លារ ដោយចេញឱ្យបានក្នុងរយៈពេល ៣ ទៅ ៥ថ្ងៃ ។ ប្រទេសទាំងនេះមានការិយាល័យជាច្រើនសំរាប់ទទួលធ្វើលិខិតឆ្លងដែន រួមទាំងនៅតាមខេត្តផង ។ នៅប្រទេសកម្ពុជាវិញសព្វថ្ងៃ មានតែការិយាល័យតូចមួយនៅភ្នំពេញ ដែលជាឧបសគ្គមួយយ៉ាងច្បាស់រារាំងដល់ដំណើរការធ្វើលិខិតឆ្លងដែនឱ្យបានឆាប់ ។ វាមិនច្បាស់ទេថា តើគេរក្សាដំណើរការធ្វើលិខិតឆ្លងដែនឱ្យយូររហូតដល់ ២ខែ ដូច្នេះដោយចេតនា រឺយ៉ាងណា ដើម្បីឱ្យអ្នកដែលចង់បានឆាប់ត្រូវបង់ប្រាក់ ២២៤ដុល្លារ ហើយតើប្រាក់ ៨០ដុល្លារដែលបូកបន្ថែមនោះត្រូវគេយកទៅណា ។

រាជរដ្ឋាភិបាលកម្ពុជា បានយល់ស្របថា តម្លៃលិខិតឆ្លងដែន វាខ្ពស់ពេកហើយសំរាប់ពលករចំណាកស្រុកដែលភាគច្រើន មកពីគ្រួសារក្រីក្រ ដូច្នេះពលករទាំងនេះ ត្រូវបង់ជាផ្លូវការតែ ៤០ដុល្លារប៉ុណ្ណោះសំរាប់លិខិតឆ្លងដែនមួយ បន្ទាប់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុម័តលើបញ្ជីឈ្មោះ និងបញ្ជូនបញ្ជីទៅក្រសួងមហាផ្ទៃ ។ នៅមុនថ្ងៃទី ៥ ខែមីនា ឆ្នាំ២០០៧ លិខិតឆ្លងដែនមានតំលៃផ្លូវការត្រឹមតែ ២០ដុល្លារ ប៉ុន្តែតម្លៃជាក់ស្តែងអាចលើសពី ៥០ដុល្លារ ហើយប្រើពេល មិនឆាប់ជាង ២ខែទេ ។ ការយឺតយ៉ាវបែបនេះ បានអូសបន្លាយដំណើរការទាំងមូលនៃការបញ្ជូនពលករ ដែលអាចប៉ះពាល់ដល់ទំនុកចិត្តរបស់ពលករផ្ទាល់ និងរបស់និយោជកនៅថៃ ។ ពលករភាគច្រើនមិនអាចរង់ចាំ ៥-៦ខែ ទើបបានចេញទៅធ្វើការនៅបរទេសនោះទេ ។ ហេតុនេះ ពួកគេត្រូវបង្ខំចិត្តសុំធ្វើលិខិតឆ្លងដែនឱ្យបានក្នុងមួយសប្តាហ៍ ដោយសុខចិត្តបង់ប្រាក់ ១៥០-២០០ដុល្លារ ដោយផ្ទាល់ រឺដោយកាត់ប្រាក់ខែសងវិញ ហើយក៏ត្រូវរ៉ាប់រងបន្ទុកចំណាយមួយដ៏ធ្ងន់ ។

ប្រសិនបើពលករទាំង ២០០.០០០នាក់ ត្រូវមានលិខិតឆ្លងដែនទាំងអស់គ្នា ហើយលិខិតឆ្លងដែនមួយគិតថ្លៃត្រឹម ៥០ដុល្លារ ដូច្នេះតំលៃសរុបត្រូវជា ១០លានដុល្លារ ។ ប៉ុន្តែ ការិយាល័យតែមួយយ៉ាងតូចនៅភ្នំពេញ មិនអាចមានកំលាំងគ្រប់គ្រាន់ដើម្បីបំពេញការងារច្រើនបែបនេះឡើយ ។ ដូច្នេះ ក្រសួងមហាផ្ទៃ គួរបង្កើតការិយាល័យបន្ថែមមួយ ឬពីរទៀតនៅភ្នំពេញ ដើម្បីឱ្យការងារមានប្រសិទ្ធភាពជាងនេះ និងរកចំណូលបានច្រើនថែមទៀត ។ សំខាន់ជាងនេះទៀត ក្រសួងមហាផ្ទៃគួរតែបង្កើតការិយាល័យធ្វើលិខិតឆ្លងដែននៅតាមខេត្តសំខាន់ៗ និងបណ្តុះបណ្តាលឱ្យមន្ត្រីមានសមត្ថភាពអនុវត្តការងារ ។ វិធីនេះមិនត្រឹមតែអាចបំពេញតំរូវការដ៏ច្រើនលើសលប់របស់ប្រជាពលរដ្ឋនោះទេ ប៉ុន្តែថែមទាំងអាចជួយកាត់បន្ថយចំណាយធ្វើដំណើរសំរាប់ប្រជាពលរដ្ឋនៅតាមខេត្តទៀតផង ។ ឧទាហរណ៍ ខេត្តបន្ទាយមានជ័យ បាត់ដំបង និងព្រៃវែង គួរមានការិយាល័យសំរាប់ទទួលពាក្យស្នើសុំ និងធ្វើលិខិតឆ្លងដែន ពីព្រោះនៅទីនោះមានពលករច្រើន ដែលត្រូវការលិខិតឆ្លងដែន ។

*បញ្ហារត់ចោលការងារនៅពេលធ្វើការនៅប្រទេសថៃ*

ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករទទួលរ៉ាប់រងចំណាយបញ្ជូនពលករ គឺជាបញ្ហាមួយ ។ ទីភ្នាក់ងារនឹងខាតបង់ ប្រសិនបើពលករគេចចេញពីការងារជាប់កិច្ចសន្យា ។ យោងតាមទីភ្នាក់ងារជ្រើសរើសពលករ ការរត់ចោលការងារមានអត្រាខ្ពស់គួរសម ជាពិសេសនៅថៃ ។ រឿងនេះអាចយល់បាន ពីព្រោះនៅថៃមានពលករកម្ពុជាតែ ៦១១៤នាក់ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅដោយស្របច្បាប់ ប៉ុន្តែមានពលករកម្ពុជាប្រហែល ១៨០.០០០នាក់ទៀត ដែលកំពុងធ្វើការដោយខុសច្បាប់ ។ ពលករស្របច្បាប់ទំនងជាចង់រត់គេចពីបំណុល ដោយទៅចូលរួមជាមួយពលករដែលគ្មានឯកសារបញ្ជាក់ ។ រឿងនេះ មិនមែនមានតែនៅថៃទេ ។ Dang. (2007) បានរាយការណ៍ថា អត្រារត់ចោលការងាររបស់ពលករវៀតណាមនៅជប៉ុន គឺ ២៧-៣០% នៅកូរ៉េខាងត្បូង ២០-២៥% ហើយនៅតៃវ៉ាន់ ៩-១២% ។

បញ្ហាមួយទៀតគឺ ពលករមួយចំនួនយល់ថា ការងារនៅថៃលំបាកពេក ដូច្នេះពួកគេប្រើគ្រប់មធ្យោបាយដើម្បីត្រឡប់មកផ្ទះវិញ ។ រឿងនេះ ធ្វើឱ្យទីភ្នាក់ងារខាតបង់ប្រាក់ ដែលខ្លួនបានចំណាយមុនដើម្បីបញ្ជូលពលករទៅធ្វើការ ។ វាអាចមកពីទីភ្នាក់ងារមិនបានពន្យល់សព្វគ្រប់ដល់ពលករ រឺក៏អាចមកពីការងារដែលទីភ្នាក់ងារបានសន្យា និងការងារពិតវាមិនដូចគ្នា ។ ទីភ្នាក់ងារ ឬក្រុមហ៊ុនជ្រើសរើសពលករ ក៏មានកំហុសមួយចំណែកដែរក្នុងរឿង ពលកររត់ចោលការងារ ពីព្រោះពួកគេជ្រើសរើសពលករមិនបានត្រឹមត្រូវល្អទេ គឺអ្នកណាក៏យកដែរឱ្យតែបានច្រើន ដើម្បីទទួលបានឆាប់ៗនូវកំរៃសំរាប់ការជ្រើសរើស ។

វាមិនមែនជារឿងងាយស្រួលទេសំរាប់ទីភ្នាក់ងារ ក្នុងការដោះស្រាយបញ្ហាពលកររត់ចោលការងារ ។ ក្នុងករណីខ្លះ ពួកគេស្នើសុំស្ថានទូតថៃអោយជួយរារាំងពលកររត់ចោលការងារ ដោយមិនផ្តល់ទិដ្ឋាការឱ្យទៀត ។ ប៉ុន្តែស្ថានភាពនៅតែច្របូកច្របល់ និងគ្មានដំណោះស្រាយល្អដដែល ។ ខុសគ្នាពីកូរ៉េខាងត្បូង រឺម៉ាឡេស៊ី ដែលមានពលករចំណាកស្រុកភាគច្រើនស្របច្បាប់ និងមិនងាយត្រឡប់មកផ្ទះវិញស្រួលៗដោយគ្មានលិខិតឆ្លងដែននោះ ប្រទេសថៃ គឺជាករណីពិសេស ពីព្រោះទីតាំងភូមិសាស្ត្រ និងការត្រួតពិនិត្យព្រំដែនធូររលុង បានផ្តល់ការងាយស្រួលដល់ពលករក្នុងការរត់ចោលការងារ ហើយបន្តស្នាក់នៅថៃនិងធ្វើការដោយមិនស្របច្បាប់ រឺរត់ត្រឡប់មកផ្ទះវិញ ។

*ការតំរូវឱ្យទីភ្នាក់ងារជ្រើសរើសពលករ ចំណាយជាមុនក្នុងការបញ្ជូនពលករចំណាកស្រុក*

បញ្ហាមួយទៀតគឺ ចំណាយហិរញ្ញវត្ថុនៃការបញ្ជូនពលករទៅក្រៅស្រុក ត្រូវទទួលរ៉ាប់រងដោយក្រុមហ៊ុនជ្រើសរើសពលករ រឺនិយោជកនៅបរទេស ។ វិធីនេះមានន័យថា ក្រុមហ៊ុនត្រូវចំណាយជាមុនយ៉ាងហោចណាស់ ៦០០.០០០ ដុល្លារ ក្នុងការបញ្ជូនពលករ ១០០០នាក់ ទៅក្រៅស្រុកក្នុងមួយលើកៗ ពីព្រោះចំណាយបញ្ជូនពលករម្នាក់ គឺ ៦០០ដុល្លារ ។ នេះជាទឹកប្រាក់យ៉ាងច្រើនដែលត្រូវប្រថុយចំណាយមុន ជាពិសេសសំរាប់ក្រុមហ៊ុនកម្ពុជា ដែលមិនសូវមានទុន ប៉ុន្តែអាចមានសមត្ថភាព ។ ក្រុមហ៊ុនមួយចំនួនបានរាយការណ៍ពីការខាតបង់ច្រើនគួរសម ដែលបណ្តាលមកពីពលកររត់ចោលការងារក្នុងពេលទៅធ្វើការនៅបរទេស និងដែលធ្វើអោយក្រុមហ៊ុនពិបាកនឹងរស់រានមានជីវិត ។ ដោយបានទទួលស្គាល់ពីបន្ទុកទាំងនេះ រដ្ឋាភិបាលមិនជំទាស់ចំពោះការតំរូវឱ្យពលករអ្នកដាក់ពាក្យទៅធ្វើការនៅបរទេស បង់

ដោយខ្លួនឯងនូវថ្លៃធ្វើលិខិតឆ្លងដែន និងចំណាយជាមូលដ្ឋាន ដូចជាការពិនិត្យសុខភាពជាដើម ។ មានទីភ្នាក់ងារមួយចំនួន បានតំរូវឱ្យពលករអ្នកដាក់ពាក្យទៅធ្វើការនៅថៃ បង់ប្រាក់ ១០០ដុល្លារ ។

បើសិនជារដ្ឋាភិបាលកម្ពុជា និងថៃ ចង់អោយពលករធ្វើចំណាកស្រុកតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ ចំនួនក្រុមហ៊ុនគួរតែមានច្រើនជាងនេះ ។ នាបច្ចុប្បន្ន ចំណាយពាក់កណ្តាល រឺលើសពីនេះទៀត គឺនិយោជកថៃជាអ្នកទទួលរ៉ាប់រងដោយផ្អែកលើលក្ខខណ្ឌថា ក្រុមហ៊ុនជ្រើសរើសពលករកម្ពុជាត្រូវផ្តល់ដោយមិនយកកំរៃសេវានូវពលករថ្មី មកជំនួសពលករដែលរត់ចោលការងារ ។ វិធីនេះបានធ្វើអោយក្រុមហ៊ុនកម្ពុជា ត្រូវប្រឈមនឹងហានិភ័យយ៉ាងធំ ។

ជារឿងងាយយល់ទេដែល ពលករភាគច្រើនពុំមានប្រាក់ ៦០០ដុល្លារសំរាប់បង់មុន ។ ប៉ុន្តែរឿងនេះអាចដោះស្រាយបានដោយរកមធ្យោបាយជួយពលករដែលចង់ទៅធ្វើការពិតៗ អោយគេទទួលបានប្រាក់កំចីពិសេសមួយដែលអាចមាន រឺគ្មានការប្រាក់ ពីធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ កម្មវិធីឥណទានរបស់ NGO រឺគំរោងសន្សំប្រាក់របស់សហគមន៍ជាដើម ។ ពលករដែលត្រូវការរកប្រាក់ឱ្យបានច្រើនពីការងារនៅក្រៅស្រុក អាចត្រូវចំណាយប្រាក់ផ្ទាល់ រឺខ្ចីប្រាក់គេសំរាប់បង់អោយទីភ្នាក់ងារជ្រើសរើសពលករ ។ ប្រាក់កំចី អាចមានការធានាពីអាជ្ញាធរមូលដ្ឋានដែលស្គាល់ពលករនោះច្បាស់ រឺមានរបៀបរៀបចំផ្សេងៗសំរាប់ជួយធានាការសងប្រាក់វិញ ។

### *ការអនុវត្តអនុស្សារណៈព្រមព្រៀងរវាងកម្ពុជា និងថៃ*

ជាផ្នែកមួយនៃការអនុវត្តអនុស្សារណៈព្រមព្រៀង (MOU) រវាងថៃ និងកម្ពុជា រដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយមានតំណាងមកពីក្រសួងការងារ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងការបរទេស ដើម្បីផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាដែលកំពុងធ្វើការក្នុងប្រទេសថៃ ដោយមិនស្របច្បាប់ ។ ក្រុមការងារថៃដែលមានសមត្ថកិច្ចប្រហាក់ប្រហែល (មានសមាជិកមកពីក្រសួងការងារ ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល) ជាអ្នកផ្តល់លិខិតអនុញ្ញាតឱ្យធ្វើការ ។ ពលករចំណាកស្រុកត្រូវចំណាយ ១៥០០បាត ទៅឱ្យគណៈកម្មាធិការកម្ពុជា និង ៤០០០បាត ទៅឱ្យគណៈកម្មាធិការថៃសំរាប់លិខិតអនុញ្ញាតការងារ ដែលតំរូវឱ្យមានការពិនិត្យសុខភាពសំរាប់ដាក់បញ្ចូលទៅក្នុងប្រព័ន្ធធានាសុខភាព ។ តំលៃសរុបនៃការបញ្ជូនពលករម្នាក់តាមរយៈប្រព័ន្ធ MOU គឺ ៧០០ដុល្លារ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា យល់ឃើញថា ក្នុង៥ឆ្នាំកន្លងមកនេះ MOU បាននិងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅថៃឱ្យមានការទទួលស្គាល់ និងការចាត់ចែងដោយយុត្តិធម៌ ។ យោងតាមការសំភាសជាមួយមន្ត្រីកម្ពុជា ក្រុមការងារផ្សេងៗដែលធ្វើការអោយក្រសួងការងារកម្ពុជា និងថៃ បានសហការគ្នាយ៉ាងល្អ ។ កិច្ចប្រជុំរវាងក្រសួងការងារកម្ពុជា និងថៃ នៅសៀមរាប កាលពីចុងខែវិច្ឆិកា ឆ្នាំ២០០៧ បានសំរេចនូវកិច្ចព្រមព្រៀងមួយថា គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាដែលធ្វើការនៅថៃ គឺអាចបន្តការងាររហូតដល់ចុងខែមិថុនា ឆ្នាំ២០០៨ ។ម្យ៉ាងទៀតក៏មានសេចក្តីសំរេចបង្កើតគណៈកម្មាធិការមួយនៅកម្ពុជា សំរាប់ទទួលពលករមិនស្របច្បាប់ដែលត្រូវគេបញ្ជូនមកវិញ នៅពេលលិខិតអនុញ្ញាតឱ្យស្នាក់នៅនិងធ្វើការ នៅថៃបានផុតកំណត់ ។ កិច្ចប្រជុំក៏បានសំរេចថា គួរមានអនុស្សារណៈព្រមព្រៀង (MOU) ថ្មីមួយសំរាប់ដោះស្រាយបញ្ហាពលករចូលទៅធ្វើចំការនៅដីថៃនៅជិតព្រំដែន ។

ជាទូទៅ គួរមានគ្រឿងលើកទឹកចិត្តផ្តល់អោយនិយោជកថៃ ដែលរួមសហការ និងការដាក់ពិន័យចំពោះនិយោជកអ្នកមិនសហការ ។ អ្នកឆ្លើយសំភាសន៍មួយចំនួនយល់ថា និយោជកថៃមួយចំនួនចូលចិត្តជួលពលករ ដែលគ្មានឯកសារបញ្ជាក់ ពីព្រោះវាចំណេញជាង ហើយពួកគេអាចធ្វើបាបពលករតាមចិត្តចង់ ។ មានគេនិយាយថា មួយថ្ងៃ-ពីរថ្ងៃមុនពេលបើកប្រាក់ខែ និយោជកថៃសហការជាមួយប៉ូលីសរករឿងដេញពលករចេញ ហើយយកប្រាក់ខែនោះ មកចែកគ្នាជាមួយប៉ូលីស ។បើសិនរឿងនេះជាការពិត គួរមានគ្រឿងលើកទឹកចិត្តសំរាប់អោយនិយោជកថៃ ណែនាំពលករខុសច្បាប់របស់ខ្លួនឱ្យទៅចុះបញ្ជី និងការផាកពិន័យ បើសិនមិនបានធ្វើដូច្នេះ ។

## សន្ទេបអនុសាសន៍

ចំណាយសំរាប់ពលករចំណាកស្រុកទៅថៃដោយស្របច្បាប់ គួរតែកាត់បន្ថយដោយចាត់វិធានការណ៍មួយចំនួន ដូចជា ១) ការរៀបចំខាងស្ថាប័ន គួរមានការកែលំអ ២) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរមាននាយកដ្ឋានមួយសំរាប់ទទួលបន្ទុកលើចំណាកស្រុកពលករ និងគួរបន្ថែមបុគ្គលិកមានសមត្ថភាពឱ្យបានច្រើន សំរាប់ដោះស្រាយបញ្ហាចំណាកស្រុក ៣) គោលនយោបាយចំណាកស្រុក និងក្របខណ្ឌច្បាប់ ដូចជា ច្បាប់អន្តោប្រវេសន៍ គួរមានការពិនិត្យកែសំរួល ៤) ថ្លៃធ្វើលិខិតឆ្លងដែន គួរកាត់បន្ថយមកត្រឹម ៥០ដុល្លារ ក្នុងរយៈពេល ១០ថ្ងៃ និង ៥) ក្រសួងមហាផ្ទៃគួរបង្កើតការិយាល័យបន្ថែមទៀតសំរាប់ធ្វើលិខិតឆ្លងដែន ដោយមានទីតាំងនៅភ្នំពេញ និងនៅតាមខេត្តសំខាន់ៗ ដូចជា បាត់ដំបង បន្ទាយមានជ័យ និងព្រៃវែង ។

ក្រុមហ៊ុន និងការិយាល័យជ្រើសរើសពលករ គួរមានច្រើនថែមទៀតនៅតាមខេត្តដែលមានពលករធ្វើចំណាកស្រុកទៅថៃច្រើន ។ អនុក្រឹត្យលេខ ៥៧ គួរមានការពិនិត្យកែតំរូវឡើងវិញ ដើម្បីឱ្យសមស្របនឹងការវិវត្តនាពេលថ្មីៗ ។ ប្រាក់តម្កល់សំរាប់បើកទីភ្នាក់ងារជ្រើសរើសពលករ (១០០.០០០ដុល្លារ នាបច្ចុប្បន្ន) គួរតែកាត់បន្ថយ ដើម្បីបង្កើនចំនួនទីភ្នាក់ងារប្រភេទនេះ ។ ទីភ្នាក់ងារនានា គួរជ្រើសរើសពលករដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាង មានពលករច្រើនរត់ចោលការងារ ។ រឿងនេះក៏អាចធ្វើឡើងដោយមានការសហការពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) ផងដែរ ។ ទន្ទឹមនឹងនេះ គួរអនុញ្ញាតឱ្យទីភ្នាក់ងារយកកំរៃសេវាអំពីពលករដែលចង់ទៅធ្វើការនៅថៃ រឺប្រទេស ផ្សេងទៀត ពីព្រោះវិធីនេះ អាចជួយកាត់បន្ថយចំនួនពលកររត់ចោលការងារ ។

ប្រទេសថៃជាអ្នកទទួលប្រយោជន៍ពីពលករចំណាកស្រុក ហេតុនេះរដ្ឋាភិបាលថៃគួរជួយឱ្យពលករទាំងនោះមានលក្ខណៈផ្លូវការ ។ រដ្ឋាភិបាលថៃគួរចូលរួមចំណែកកាត់បន្ថយចំណាយរត់ការផ្សេងៗ (សំរាប់លិខិតអនុញ្ញាតការងារ និងទិដ្ឋាការ) និងគួរចាត់វិធានការបញ្ឈប់ការជួលពលករមិនស្របច្បាប់ ។ គ្រឿងលើកទឹកចិត្ត គួរផ្តល់ឱ្យនិយោជក ដែលជួលពលករស្របច្បាប់ រីឯអ្នកជួលពលករមិនស្របច្បាប់គួរតែទទួលការពិន័យ ។ ចំពោះពលករកំពុងធ្វើការនៅថៃ គួរមានវិធីជួយពួកគេឱ្យមានសិទ្ធិធ្វើការនៅទីនោះដោយស្របច្បាប់ ដោយមិនចាំបាច់ឱ្យពួកគេមកធ្វើលិខិតឆ្លងដែន និងសុំទិដ្ឋាការនៅភ្នំពេញទេ ។ គួរមានការកាត់បន្ថយរាល់ចំណាយដែលពាក់ព័ន្ធនឹងការបញ្ជូនពលករស្របច្បាប់ ។

*តទៅទំព័រទី ១៧*

# ការគ្រប់គ្រងធនធានទឹក នៅប្រទេសកម្ពុជា: ប្រវត្តិ និងបញ្ហាប្រឈម នាអតីតកាល និងបច្ចុប្បន្ន

*ចែម ផល្លា និង David Craig បានដកស្រង់មេរៀនពីបទពិសោធន៍មុនៗ និងបញ្ហាគន្លឹះមួយចំនួនដែល ការគ្រប់គ្រងធារាសាស្ត្រកំពុងជួបប្រទះ ។ អ្នកទាំងពីរ ក៏បានពិនិត្យពីរបៀបដែលសង្គមកម្ពុជានៅអំឡុងពេលខុសៗគ្នា បានប្រើប្រាស់ទឹកនៅក្នុងការអភិវឌ្ឍអរិយធម៌ ។**

## សេចក្តីផ្តើម

ធនធានទឹក គឺចំណុចស្នូលក្នុងជីវិតរស់នៅ វប្បធម៌ សេដ្ឋកិច្ច និងភូមិសាស្ត្ររបស់កម្ពុជាតាំងពីយូរណាស់មកហើយ ។ ដោយសារប្រទេសកម្ពុជាឧស្សាហ៍ជួបស្ថានភាពមានទឹកច្រើនពេក រឺតិចពេកអាស្រ័យទៅតាមរដូវ និងទីតាំងភូមិសាស្ត្រ ការគ្រប់គ្រងទឹកគឺជាបញ្ហាចំបងមួយដែលអ្នកគ្រប់គ្រងប្រទេសគ្រប់ជំនាន់បានរិះរកមធ្យោបាយដោះស្រាយទៅតាមករិតខុសៗគ្នា ។ នៅពេលគ្រប់គ្រងបានល្អ ទឹកគឺជាប្រភពនៃជីវភាពរុងរឿង ។ ផ្ទុយទៅវិញ បើសិនពុំមានអភិបាលកិច្ចល្អទេ ទាំងទ្រព្យសម្បត្តិ និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ក៏គ្មានចីរភាពដែរ ។

អត្ថបទនេះ បានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក (WRMRCDP) និងមានគោលដៅចងក្រងមេរៀនបានមកពីបទពិសោធន៍នៅអតីតកាល ព្រមទាំងបញ្ហាសំខាន់ៗមួយចំនួន ដែលកំពុងចោទឡើងក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ អត្ថបទនេះ ចាប់ផ្តើមពិនិត្យមើលថា តើសង្គមកម្ពុជា នៅតាមសម័យកាលខុសៗគ្នា បានយល់ឃើញយ៉ាងណាពីធនធានទឹកក្នុងការអភិវឌ្ឍអារ្យធម៌របស់ខ្លួន ។ បន្ទាប់មកទៀត មានការបកស្រាយពីបញ្ហាចំបងៗនាពេលថ្មីៗលើការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ តាមរយៈការសិក្សាលើអាងស្តុកទឹកម្លេច នៅខេត្តកំពត ។ ការសិក្សាមានគោលដៅរកអោយឃើញថាតើទឹកបានយកមកប្រើធ្វើអ្វីខ្លះ, តើសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) បំពេញមុខងារបានល្អកំរិតណាទាក់ទិននឹងប្រតិបត្តិការ ការថែទាំជួសជុល និងការដោះស្រាយទំនាស់ និង តើប្រព័ន្ធធារាសាស្ត្រមានផលប៉ះពាល់យ៉ាងណាដល់ការចិញ្ចឹមជីវិតនៅជនបទ ។

* អត្ថបទនេះ ផ្អែកលើក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក (WRMRCDP) ។ លោក ចែម ផល្លា ជាអតីតអ្នកដឹកនាំក្រុមស្រាវជ្រាវនៅក្នុងកម្មវិធី WRMRCDP ហើយពេលនេះ កំពុងសិក្សាថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យស៊ីដនី ។ លោក David Craig ជាទីប្រឹក្សាកម្មវិធី WRMRCDP ។

## សង្ខេបពីការគ្រប់គ្រងធនធានទឹកនៅអតីតកាល

ផ្នែកនេះ ពិនិត្យត្រួសៗពីការគ្រប់គ្រងធនធានទឹកនៅសម័យកាលខុសៗគ្នា ចាប់ពីសម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណានិគមបារាំង សម័យសម្តេចនរោត្តមសីហនុ និងសម័យប៉ុលពត ។

### សម័យមុនអង្គរ

ប្រវត្តិសាស្ត្រកម្ពុជា មានព័ត៌មានច្បាស់លាស់ចាប់ពីសតវត្សរ៍ទី២ នៅពេលដែលប្រទេសនេះមានឈ្មោះថា "ហ្វូណន" ។ នៅសម័យហ្វូណន សេដ្ឋកិច្ចមានមូលដ្ឋានចេញមកពីការធ្វើជំនួញ ប៉ុន្តែចាប់តាំងពីសតវត្សរ៍ទី៧ បានពឹងផ្អែកលើកសិកម្មវិញ ដូចជាការធ្វើស្រែប្រាំង ស្រែវស្សា ការដាំដុះដំណាំមើម (Feeny 1982: 35-38 cited in Vickery, 1998) ការចិញ្ចឹមសត្វសំរាប់ធ្វើអាហារ ព្រមទាំងសិប្បកម្មដូចជាតំបាញ ដេរប៉ាក់ និងការធ្វើលោហៈផលិតគ្រឿងអលង្ការ ជាដើម (Chandler, 1993: 15-16) ។ យោងតាមកំណត់ហេតុរបស់ចិន ស្តីពីវិស័យកសិកម្មនៅសម័យហ្វូណន (Vickery M. 1998: 19; Chandler 1993: 6) សង្គមសម័យហ្វូណន អនុវត្តបច្ចេកទេសទំនើបក្នុងការគ្រប់គ្រងធនធានទឹក និងដាំស្រូវ ។ កសិករស្តុកទឹកក្នុងអាងដែលកសាងឡើងសំរាប់ងូត និងស្រោចស្រពដំណាំ (Chandler 1993: 6) ។ ការដាំដុះស្រូវនៅសម័យនោះ ផ្តល់ផលលើសពីតំរូវការ ហើយផលស្រូវលើស បានប្រើការសំរាប់ដោះដូរយកក្រណាត់ និងទំនិញផ្សេងៗទៀតដែលមានជួញដូរនៅតាមបណ្តោយដងទន្លេ ។

### សម័យអង្គរ

សម័យអង្គរ (គ.ស ៨០២-១៤៣១) ទទួលបានជោគជ័យលើការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងទឹក ។ ទឹកភ្លៀង និងទឹកជំនន់ទន្លេមេគង្គ គេប្រមូលនិងស្តុកវាទុកក្នុងអាងស្តុកដែលបានសាងឡើងសំរាប់ការស្រោចស្រព និងប្រើប្រាស់ក្នុងគ្រួសារ។ បារាយណ៍ទឹកថ្លាខាងលិច ជាឧទាហរណ៍ដ៏ល្អមួយនៃ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ដែលប្រើនៅសម័យអង្គរ និងបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ។ នៅសម័យនោះ តំបន់អង្គរប្រមូលផលស្រូវបានច្រើនដងក្នុងមួយឆ្នាំ។ ផលិតភាពស្រូវដ៏ខ្ពស់បែបនេះ បានជួយពង្រឹងយ៉ាងខ្លាំងដល់សេដ្ឋកិច្ចប្រទេស និងបង្កើនភាពរុងរឿង ។ កំណត់ហេតុជីវតាខ្វាន់ ស្តីពីសម័យអង្គរ (១២៩៦-១២៩៧) បានបញ្ជាក់ថា ការប្រមូលផលស្រូវពីបីទៅបួនដងក្នុងមួយឆ្នាំ អាចធ្វើទៅបានដោយផ្អែកលើកំលាំងពលកម្មដែលរស់នៅផ្តុំគ្នា ដីមានជីជាតិ និងប្រព័ន្ធស្តុកទឹកដ៏ល្អឥតខ្ចោះ (Chandler 1993: 74) ។

នៅចុងសម័យអង្គរ (សតវត្សរ៍ទី១៣ រឺទី១៤) ការគ្រប់គ្រងទឹកមានជោគជ័យល្អនេះ បានចុះអន់ខ្សោយដែលអាចបណ្តាលពីហេតុផលជាច្រើនរួមផ្សំគ្នាដូចជា ការវាយប្រហារពីថៃ/បរទេសផ្សេងទៀត និង/រឺទំនាស់ផ្ទៃក្នុង ដែលបានកេណ្ឌប្រមូល មួយភាគធំនៃកំលាំងពលកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក ដើម្បីបញ្ជូនទៅធ្វើសង្គ្រាម ។ ជាបណ្តើរៗ ប្រព័ន្ធគ្រប់គ្រងទឹកក៏ត្រូវខូចខាត មិនអាចប្រើប្រាស់បាន។ ម្យ៉ាងទៀត ការខូចខាតក៏អាចបណ្តាលពីកត្តាធម្មជាតិផងដែរ ។

### សម័យក្រោយអង្គរ

ដូចបានរៀបរាប់ខាងលើ នៅចុងសម័យអង្គរ និងនៅមុនរបបអាណានិគមបារាំង សេដ្ឋកិច្ចប្រទេសកម្ពុជាបានធ្លាក់ចុះអន់ខ្សោយក្លាយជាសេដ្ឋកិច្ច

គ្រាន់តែមួយរស់ៗ ហើយប្រជាជនចំណាយពេលភាគច្រើនទៅលើការដាំដុះស្រូវ ។ ផលស្រូវលើសតំរូវការ កំរមានណាស់នៅសម័យនោះ ហើយការសន្សំក៏មានកំរិតទាប ។ យោងទៅតាម Minh Mang (1843) ដែលមានចុះក្នុងឯកសារ Chandler (1993) អ្នកភូមិច្រើនប្រើស្រះទឹកដើម្បីស្តុកទឹកស្រោចស្រពដំណាំ ប៉ុន្តែមិនមានទំនប់អាងស្តុកទឹក រឺក៏ប្រព័ន្ធប្រឡាយ ដូចកាលពីសម័យអង្គរឡើយ ។ នៅពេលនោះ ប្រជាជនមានចំនួនតិច គ្មានគ្រឿងលើកទឹកចិត្ត ហើយកសិករមានបច្ចេកទេសតិចតួចសំរាប់ជាជំនួយក្នុងការធ្វើចំរុះកម្មដំណាំ រឺអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងទឹក ។

## សម័យអាណានិគមបារាំង

ប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមបារាំងចាប់ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ។ នៅខែសីហា ឆ្នាំ១៨៦៣ ព្រះបាទនរោត្តម បានយល់ព្រមដាក់ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលរបស់បារាំង ។ សន្ធិសញ្ញាជាមួយបារាំងបានកំណត់ឱ្យបារាំងផ្តល់កិច្ចការពារសំរាប់ប្រទេសកម្ពុជា និងផ្តល់សិទ្ធិអោយបារាំងគ្រប់គ្រងសម្បទានឈើហ៊ុប និងការរុករករ៉ែនៅកម្ពុជា ។ ប្រជាជនកម្ពុជានៅអំឡុងទសវត្សរ៍១៨៦០ មានតិចជាងមួយលាននាក់ (ផ្អែកតាមឯកសារប្រមូលពន្ធ) ហើយប្រជាជនជាង ៩៥% រស់នៅតាមជនបទ ។ ពួកគេជាកសិករពឹងផ្អែកលើការធ្វើស្រែបានត្រឹមមួយរស់ៗ ត្រូវបង់ពន្ធខ្ពស់ទៅអោយបារាំង ហើយសេដ្ឋកិច្ចកម្ពុជានាសម័យនោះមានស្ថានភាពមិនល្អទេ (Chandler 1993: 100) ។

ទោះអន់ខ្សោយខ្លាំងក្តី ក៏សេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមរីកលូតលាស់យឺតៗឡើងវិញ ជាពិសេសពីត្រឹមទសវត្សរ៍១៩២០ ដោយសារនៅពេលនោះមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។ ការអភិវឌ្ឍផ្លូវថ្នល់បានជួយសំរួលការនាំចេញអង្ករ ដែលឡើងដល់ ១០០.០០០តោន/ឆ្នាំ និងការនាំចេញផលិតផលចំការកៅស៊ូដែលធ្វើជាមួយសហគ្រាសបារាំង និងចិន (Chandler 1993: 160, 162) ។ ការនាំចេញអង្ករ ដើរតួនាទីយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចនៅជនបទ ដោយជួយបង្កើនការផលិតដើម្បីបំពេញតំរូវការអន្តរជាតិ និងផ្តល់ចំណូលពន្ធដែលបានបង្វែរយកមកចំណាយលើការងារសាធារណៈ ដូចជាផ្លូវថ្នល់ អគ្គិសនី និងការអប់រំ ។

## សម័យសម្តេចនរោត្តមសីហនុ

ព្រះបាទនរោត្តមសីហនុ ឡើងគ្រងរាជ្យក្នុងឆ្នាំ១៩៤១ ហើយព្រះអង្គបានបំផុសពីគំរូល្អនៃគោលនយោបាយ និងការអភិវឌ្ឍ រចនាសម្ព័ន្ធគ្រប់គ្រងទឹកនៅសម័យអង្គរ។ ព្រះអង្គបានបង្កើតគំរោងខ្លួនទីពឹងខ្លួន ដោយបញ្ចូលអ្នកជំនាន់ក្រោយ អោយអនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានទឹក ។ ក្នុងឆ្នាំ១៩៥៨ ព្រះអង្គមានព្រះបន្ទូលថា: "ប្រជាជនត្រូវតែមានទឹកគ្រប់គ្រាន់សំរាប់ហូប និងសំរាប់ធ្វើស្រែ ទោះនៅរដូវប្រាំងក៏ដោយ" (Than 1982: 24, cited in Öjendal 2000: 180) ។ ប៉ុន្តែចំណេះដឹងនៅមានតិចតួចនៅឡើយ ស្តីពីរបៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងទឹកពីបុរាណឱ្យមានទ្រង់ទ្រាយធំជាងមុន ។

## សម័យប៉ុលពត

របបកម្ពុជាប្រជាធិបតេយ្យ កាន់កាប់ប្រទេសកម្ពុជាចាប់ពីខែមេសា ១៩៧៥ ដល់ ១៩៧៨ ។ របបនេះចាត់ទុកស្រូវ ជាធនធានសេដ្ឋកិច្ចសំខាន់បំផុត ហើយបានលើកផែនការមានមហិច្ឆិតាខ្ពស់ដោយត្រូវផលិតស្រូវឱ្យបានលើសពី ៧តោន/ហិកតា ។ ដើម្បីសំរេចផែនការនេះ ប៉ុលពតបានបង្ខំប្រជាជនទូទាំងប្រទេសអោយធ្វើពលកម្មដាំដុះស្រូវ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទឹក ដូចជា កសាងទំនប់ទឹក និងបណ្តាញប្រឡាយ ជាដើម។ ក្នុងសេចក្តីថ្លែងការណ៍នៅទីក្រុងភ្នំពេញ នាថ្ងៃទី១០ តុលា ១៩៧៨ ប៉ុលពតបាននិយាយថា " អាទិភាពទី១ កម្ពុជាប្រជាធិបតេយ្យត្រូវតែ... ... ផលិតស្រូវអោយបានច្រើនជាងប្រទេសជប៉ុន... ដែលអាចផលិតបាន ៧តោន/ហិកតា" (Martin 1983: 1, cited in Öjendal 2000) ។

ប៉ុល ពត ផ្តោតលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ សំរាប់ជាមធ្យោបាយធ្វើអោយកម្ពុជាក្លាយជាប្រទេសអាចផលិតស្រូវ បានគ្រប់គ្រាន់សំរាប់តំរូវការក្នុងស្រុក និងមានផលស្រូវលើសតំរូវការថែមទៀត។ ប៉ុល ពត មើលឃើញ តំបន់ពាយ័ព្យជាកន្លែងមានផលិតភាពល្អអាចជួយអោយសំរេចបានផលស្រូវលើសពីតំរូវការ ដូច្នេះ "ប្រជាជនថ្មី"[១] ស្ទើរតែទាំងអស់ត្រូវបានជំលៀសបញ្ជូនទៅធ្វើស្រែនៅទីនោះ ។ យោងតាមផែនការ ៤ឆ្នាំរបស់ខ្លួន ប៉ុល ពត បានដាក់ផែនការបង្កើនទិន្នផលស្រូវទូទាំងប្រទេសអោយបានជាមធ្យមដល់ ៣តោន/ហិកតា ដោយជំរុញអោយមានការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រយ៉ាងទូលំទូលាយ ការប្រមូលផលស្រូវពីរឺបីដងក្នុងមួយឆ្នាំ និងការកំណត់ម៉ោងធ្វើការយ៉ាងវែង ។ ប៉ុន្តែផែនការរយៈ ៤ឆ្នាំនេះបានកំណត់ឡើងដោយគ្មានការសិក្សាថា តើទិន្នផលនេះអាចសំរេចបានរឺទេក្នុងលក្ខខណ្ឌធនធានទឹក និងប្រភេទដីដែលមានស្រាប់ រឺក៏ហេដ្ឋារចនាសម្ព័ន្ធប្រភេទណាដែលសមស្របនឹងផែនការនេះ ។ ផ្ទុយទៅវិញ ប៉ុល ពត បានប្រកាសអោយប្រជាជនទាំងអស់ "វាយសំរុកគ្រប់មុខព្រួញ" (Chandler 1993: 211-216) ។

ជាលទ្ធផល ក្នុងអំឡុងពេលនោះ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រភាគច្រើនសាងសង់មិនបានល្អ និងមិនបានរួចរាល់ជាស្ថាពរទេ ហើយក៏គ្មានការសិក្សាវាយតំលៃខាងធារាសាស្ត្ររឺស្ថានភាពដីដែរ ដែលបង្កបញ្ហាជាច្រើនដល់ការគ្រប់គ្រង និងការថែទាំ ជួសជុល ។ លោក Halcrow បានសន្និដ្ឋានថា ប្រព័ន្ធធារាសាស្ត្រដែលសាងសង់ក្នុងអំឡុងរបបខ្មែរក្រហម អាចប្រើប្រាស់ឡើងវិញបាន បើសិនមានការស្តារជួសជុលតាមបច្ចេកទេសត្រឹមត្រូវ ដើម្បីជួយសំរួលអោយការគ្រប់គ្រងមានចីរភាព និងញ៉ាំងអោយវាអាចបំពេញមុខងារបានច្រើនជាអតិបរមា (1994, cited in Öjendal, 2000) ។

## បញ្ហាប្រឈមនាបច្ចុប្បន្នចំពោះការគ្រប់គ្រងធនធានទឹក

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនៅខែមករា ១៩៧៩ ប្រទេសកម្ពុជា ចាប់ផ្តើមកសាងជាតិឡើងវិញ តាមរយៈការកែតំរូវរចនាសម្ព័ន្ធនយោបាយទៅអនុវត្តគោលការណ៍ប្រជាធិបតេយ្យ ការកែលំអសន្តិសុខស្បៀងដោយពង្រឹងវិស័យកសិកម្ម និងការកែលំអគោលនយោបាយគ្រប់គ្រងទឹកដើម្បីញ៉ាំងឱ្យការប្រើប្រាស់ធនធានទឹកមានចីរភាព ។ ប៉ុន្តែ ការងារគ្រប់គ្រងធនធានទឹក ភាគច្រើនលំបាកស្មុគស្មាញ ដោយសារខ្វះខាតបច្ចេកទេស និងហិរញ្ញវត្ថុ ។ ការរចនារៀបចំខាងបច្ចេកទេស និងវិនិយោគហិរញ្ញវត្ថុ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើជំនួយគាំទ្រពីអង្គការអន្តរជាតិ (IOs) និងកម្មវិធីជំនួយអន្តរជាតិនានារបស់អង្គការសហប្រជាជាតិ ។

នៅអំឡុងពេលនោះ ប្រព័ន្ធធារាសាស្ត្រភាគច្រើន បានសាងសង់ទៅតាមតំរូវការចាំបាច់ភ្លាមៗ ដោយគ្មានពិចារណាពីចីរភាពយូរអង្វែង រឺវិធីសាស្ត្រគ្រប់គ្រងគ្រប់ជ្រុងជ្រោយនោះទេ ។ សព្វថ្ងៃ តំបន់ធំៗជាច្រើននៅកម្ពុជាមិនទាន់មានសន្តិសុខ ហើយខ្វះខាតការសំរបសំរួលក្នុងដំណើរការរចនារៀបចំគំរោង ។ ជាលទ្ធផល ប្រព័ន្ធធារាសាស្ត្រជាច្រើនដែលបានស្តារជួសជុល ក្នុង

ទសវត្សរ៍១៩៨០ និង ១៩៩០ មិនអាចដំណើរការបានពេញលេញ ហើយភាគច្រើនធ្វើបានរួចរាល់តែមួយភាគ នាំអោយលំបាកស្មុគស្មាញដល់ការគ្រប់គ្រងទឹកនាបច្ចុប្បន្ន បង្កការផ្លាស់ប្តូរលំហូរទឹក ការខូចខាតប្រព័ន្ធស្ទឹង-ទន្លេ និងការប៉ះពាល់ដល់ការងារស្រោចស្រព ។

នៅទសវត្សរ៍មុននេះ តំបន់ធ្វើស្រែពឹងទឹកភ្លៀង និងស្រែប្រាំងខ្លះ ត្រូវបានពង្រឹងតាមរយៈការផ្តល់ប្រព័ន្ធធារាសាស្ត្របន្ថែមទៀត ដោយបានជំនួយហិរញ្ញវត្ថុពីអង្គការអន្តរជាតិផ្សេងៗ ដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ជាក់ស្តែង ២៩៣ប្រព័ន្ធធារាសាស្ត្រ ត្រូវបានសាងសង់ និង/វិស្តារជួសជុលនៅទូទាំងប្រទេស ចាប់ពីឆ្នាំ១៩៩៩ ដល់ ២០០៦ ។ ប្រព័ន្ធទាំងនេះផ្តល់សុវត្ថិភាពទឹកសំរាប់ការធ្វើស្រែលើផ្ទៃដីជាង ៧១៦.៤៩៣ហិកតា (រឺ ៣២% នៃផ្ទៃដីស្រែទាំងអស់) ។ ទំនប់គ្រប់គ្រងទឹកជំនន់តាមដងរពឹទន្លេមេគង្គ ផ្តល់ការការពារលើផ្ទៃដីជាង ១៣០.៩៥០ ហិកតា ព្រមទាំង ទំនប់ទឹកសមុទ្រផ្តល់ការការពារលើផ្ទៃដីជាង ១៨.៣៩០ ហិកតា (Sakhon Veng 2007) ។

## ករណីសិក្សាពីអាងទឹក ម្លេច ក្នុងខេត្តកំពត

### វិធីសាស្ត្រ

អាងទឹកម្លេច បានជ្រើសយកមកធ្វើជាករណីសិក្សាមួយជាបន្ថែមលើការសិក្សាលើ ១៨ប្រព័ន្ធធារាសាស្ត្រ នៅជុំវិញបឹងទន្លេសាប ។ អាងទឹកម្លេចមានទីតាំងនៅក្នុងឃុំច្រេះ ស្រុកជុំគីរី ខេត្តកំពត ។ ក្រសួងធនធានទឹកបានស្តារជួសជុលវាឡើងវិញនៅឆ្នាំ២០០៤ ដោយមានការគាំទ្រខាងហិរញ្ញវត្ថុ (កំចី) និងបច្ចេកទេសពីធនាគារពិភពលោក (WB) ។ អាងទឹកម្លេច រួមមានទំនប់ទឹកមួយ ទំនប់បង្វៀរមួយ ផ្លូវបញ្ចេញទឹក និងប្រឡាយមួយចំនួន ។ អាងទឹកនេះអាចផ្ទុកទឹកបាន ១,១លានម៉ែត្រគូប និងអាចផ្តល់ទឹកសំរាប់ស្រោចស្រពបន្ថែមដល់ស្រែវស្សា ២,១៥០ហិកតា និងស្រោចស្រពពេញលេញដល់ស្រែប្រាំង ៧៥០ហិកតា ។

ការសិក្សាបានប្រើ បច្ចេកទេសវាយតំលៃតំបន់ជនបទដោយមានការចូលរួម (PRA) ដូចជា ការកសាងផែនទីគំរោង ប្រតិបត្តិការចំរុះ និងកិច្ចពិភាក្សាក្រុមស្នូល (FGD) ។ ករណីសិក្សាបានធ្វើឡើងដើម្បីប្រៀបធៀប និងដកស្រង់មេរៀនអំពី គំរូ/វិធីសាស្ត្រ ដែលទទួលមូលនិធិពីរដ្ឋាភិបាល/ម្ចាស់ជំនួយ និងគ្រប់គ្រងដោយសហគមន៍ ។ ដូច្នេះ ករណីសិក្សានេះត្រូវបានជ្រើសរើសបន្ថែមជា ករណីពិសេសស្ថិតនៅក្រៅតំបន់ទន្លេសាបសំរាប់ធ្វើការប្រៀបធៀប នៅក្នុងរយៈពេលនៃការវាយតំលៃខាងសង្គម/ស្ថាប័ន នៃការអភិវឌ្ឍកសិកម្មមានការស្រោចស្រព របស់ក្រសួងធនធានទឹក ក្នុងខែមិថុនា ឆ្នាំ២០០៧ ។

ប្រធានបទ និងបញ្ជីសំនួរមួយចំនួន បានយកមកប្រើក្នុងកិច្ចពិភាក្សាក្រុមស្នូល ដែលមានក្រុមអ្នកចូលរួមខុសៗគ្នា ។ ក្នុងការងារនេះ អ្នកចូលរួមនានាត្រូវបានជ្រើសរើសដោយមានគោលដៅច្បាស់ និងផ្តុំគ្នាជាក្រុម FGD ផ្សេងៗ ដែលរួមមាន (១) អ្នកដឹកនាំសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) (២) កសិករ (នៅខ្សែទឹកខាងលើ និងខ្សែខាងក្រោម) នៃប្រឡាយស្រោចស្រព និង (៣) សមាជិក FWUC ។

### លទ្ធផលរកឃើញ

ពិតហើយ ការស្រោចស្រពជួយឱ្យមានការចូលរួមកាន់តែទូលំទូលាយក្នុងសេដ្ឋកិច្ចមានការលក់ដូរ តាមរយៈផលស្រូវប្រាំង (ដែលខុសពីផលស្រូវវស្សាព្រោះគេយកវាទៅលក់) និងកំណើនការដាំដុះបន្លែ ។ ប្រាក់ចំណូលបន្ថែមបានដល់កសិករមានច្រើនគួរកត់សំគាល់ ទោះបីឈ្មួញកណ្តាលហាក់ដូចប្រមូលយកបានមួយភាគធំនៃផលចំណេញក្នុងខ្សែរយៈលក់ដូរកសិផលក្តី ។ កំណើនទ្រព្យកាន់កាប់ជាសត្វចិញ្ចឹម (គោ ជ្រូក មាន់ ទា) គឺជាការធានារ៉ាប់រងទី១ដ៏រឹងមាំ សំរាប់ទប់ទល់នឹងការខូចខាត ផលដំណាំ/ចំណូលផ្សេងៗ ហើយទ្រព្យសម្បត្តិងាយលក់ចេញគឺជាការធានារ៉ាប់រងទី២ ។

ទិដ្ឋភាពសេដ្ឋកិច្ចនយោបាយជាទូទៅនៅជនបទ ជាកត្តាសំខាន់ដែលកំណត់ផលប៉ះពាល់រយៈពេលវែងនៃការស្រោចស្រព ទៅលើជីវភាពរស់នៅរបស់ប្រជាជន ។ នាបច្ចុប្បន្ន លុយពិតប្រាកដដែលអាចរកបានគឺដីធ្លីនេះឯង ដែលកើនតំលៃទ្វេមួយជាពីរយ៉ាងទៀងទាត់ ទោះបីមានរឺគ្មានការស្រោចស្រពក្តី ។ លទ្ធភាពស្រោចស្រពអាចបន្ថែមតំលៃតិចតួចប៉ុណ្ណោះដល់ដីធ្លី រីឯទីតាំង និងស្ថានភាព ដីផ្សេងៗទៀត អាចបង្កើនតំលៃដីបានច្រើនណាស់ ។ ទោះបីនៅតាមឃុំដាច់ស្រយាលដែលក្រុមស្រាវជ្រាវបានទៅដល់ ក៏មានរបាយការណ៍ថា តំលៃដីបានកើនឡើងមួយជាបីក្នុងរយៈពេល២ឆ្នាំចុងក្រោយ ដែលហាក់ផុសចេញពីសកម្មភាពទិញលក់កេញយកចំណេញសុទ្ធសាធ ។ ច្បាស់ហើយ បើសិនអ្នកវិនិយោគធំៗនៅតែបន្តចូលពាក់ព័ន្ធនឹងដីកសិកម្មដែលមានប្រព័ន្ធស្រោចស្រព ទិដ្ឋភាពមួយចំនួននឹងត្រូវផ្លាស់ប្តូរជាមិនខាន ។ ពួកវិនិយោគិនអាចទុកដីនៅស្ងៀមមិនបន្តការដាំដុះយកផល រឺមិនធ្វើវិនិយោគអ្វីសោះលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ។ ទោះបីវិនិយោគិនជួលដីទៅអោយកសិករក្នុងមូលដ្ឋាន រឺបានចូលរួមដាំដំណាំលក់យកប្រាក់ជាទ្រង់ទ្រាយធំក្តី ក៏តាមដំណើរវិវត្តន៍នាពេលសព្វថ្ងៃ ការងាររបស់ FWUC ប្រហែលនឹងត្រូវផ្លាស់ប្តូរជាមិនខាន ។

នៅអាងទឹកម្លេច សេដ្ឋកិច្ចមាត្រដ្ឋានសំខាន់បំផុតដើម្បីទាញយកចំណេញពីវិនិយោគលើដំណាំលក់យកប្រាក់ ហើយរឿងនេះ អាចជាសំពាធធ្ងន់មួយទៅលើធនធាននានានៅរដូវប្រាំង ពីព្រោះកសិករធំៗជាច្រើនទាមទារយកទឹកច្រើនៗនៅរដូវប្រាំង សំរាប់ធ្វើការដាំដុះ ។ ទំហំសកម្មភាព និងឥទ្ធិពលរបស់ពួកគាត់ អាចជួយអោយគាត់មានអំណាចច្រើននៅក្នុង FWUCs រឺយ៉ាងហោចណាស់ក៏អាចបង្កទំនាស់នៅក្នុងប្រព័ន្ធសព្វថ្ងៃ ដែលមានការបែងចែកទឹកភាគច្រើនតាមលក្ខណៈប្រជាធិបតេយ្យក្នុងមូលដ្ឋាន និងមានសមធម៌គួរសមក្នុងពេលមានកង្វះខាត ។ អតុល្យភាពរវាងអ្នកប្រើប្រាស់ទឹកតូចៗជាច្រើននាក់ នឹងអ្នកប្រើប្រាស់ខ្នាតធំដែលមានទ្រព្យធន/អំណាចចោទឡើងកាន់តែខ្លាំងបើសិនមានទំនាស់ ។ មានភស្តុតាងច្រើនណាស់បង្ហាញថា នៅកម្ពុជាទំនាស់ជាច្រើននាបច្ចុប្បន្នអាចដោះស្រាយបាននៅក្នុងមូលដ្ឋាន បើសិនមានតែប្រជាជនមូលដ្ឋានចូលពាក់ព័ន្ធ។ ប៉ុន្តែសំរាប់អ្នកនៅក្រៅសហគមន៍ ដែលមានទ្រព្យ/អំណាចច្រើន ពួកគេតែងអាចធ្វើសកម្មភាពដណ្តើមលទ្ធភាព/សិទ្ធិប្រើប្រាស់ធនធាន ទៅតាមមធ្យោបាយដែលស្ថាប័នក្នុងមូលដ្ឋាន ដូចជា FWUCs ជាដើម មិនអាចធ្វើអ្វីកើតទេ ។

បញ្ចប់សេចក្តីមក អង្កេតទាំងឡាយនាបច្ចុប្បន្នស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ត្រូវតែទទួលស្គាល់ពីសារៈសំខាន់នៃគំរោងរបស់អ្នកផ្តល់ជំនួយ ព្រមទាំងបញ្ហាដែលគំរោងនីមួយៗបង្កឡើងចំពោះចីរភាព និងសមត្ថភាពក្នុងរយៈពេលវែងនៃបណ្តាស្ថាប័នថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានទឹក ។ ពិតហើយ សព្វថ្ងៃពុំទាន់មានប្រព័ន្ធធំណាមួយ ដែលបានគ្រោង រឺបានដំណើរការនៅកំរិតតំបន់ ដើម្បីកំណត់ថាតើមានអ្វីកើតឡើងក្នុងការរចនារៀបចំប្រព័ន្ធធារាសាស្ត្រនៅប្រទេសកម្ពុជាភាគច្រើន ។

ផ្ទុយទៅវិញ មានគំរោងជាច្រើនដែលពាក់ព័ន្ធនឹងការងារជាក់លាក់មួយចំនួន (ជារឿយៗ គឺសំណង់ទំនប់) ត្រូវបានផ្ដួចផ្ដើម និងកសាងដោយម្ចាស់ជំនួយនៅក្នុងសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ ។

លំនាំខាងលើអាចនាំឱ្យមានការយកប្រាក់កំរៃច្រើនៗនៅក្នុង និងនៅជុំវិញគំរោង សំរាប់ពួកអ្នកចូលរួមសកម្មក្នុងការគ្រប់គ្រងគំរោង ។ ផ្ទុយទៅវិញ ស្ថាប័នថ្នាក់ជាតិមិនសូវចង់កសាងគំរោងសំរាប់រយៈពេលវែងទេ ពីព្រោះពួកគេអាចផ្ទេរកិច្ចដំណើរការការគ្រប់គ្រង និងការថែទាំជួសជុលទៅអោយតួអង្គថ្នាក់មូលដ្ឋាន ។ ជាលទ្ធផល សំណង់ជាច្រើនដែលអាចកសាងបានជាមួយនឹងទឹកប្រាក់ដែលមានស្រាប់របស់ម្ចាស់ជំនួយ ក៏ត្រូវបានកាត់បន្ថយដូចជាខាងគុណភាពជាដើម។ លក្ខណៈមជ្ឈការនៃការធ្វើផែនការ និងអនុវត្តគំរោង មានផលប៉ះពាល់ជាច្រើនទៀត ។ សមត្ថភាពក្នុងមន្ទីរធនធានទឹកខេត្តមិនបានរីកចំរើនច្រើនទេ ។ ពួកគេត្រូវអនុវត្ត FWUCs ដោយពេលខ្លះហាក់ដូចទៅអនុវត្តនៅតាមកន្លែងដែលធ្លាប់កេណ្ឌប្រមូល FWUCs កាលពីមុនបានមួយផ្នែកហើយ។ ម្យ៉ាងទៀត ប្រសិនបើការរចនារៀបចំជាមូលដ្ឋាន និងអនុវត្តន៍ធ្វើបានល្អ (ដូចក្នុងករណីដែលយើងបានឃើញ) វិធីសាស្ត្ររបស់គំរោងគឺអាចកសាងបាននូវមូលដ្ឋានគ្រឹះមួយដ៏មានប្រយោជន៍ ។ បន្ទាប់មក គំរោងតូចៗរីដាច់ដោយដុំជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ព្រមទាំងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសេវាគាំទ្រផ្សេងៗទៀតរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អាចបង្កើតឡើងនៅជុំវិញគំរោងធំសំរាប់ជួយទ្រទ្រង់ ដោយមិនធ្វើអោយខូចខាតដល់លក្ខណៈជាមូលដ្ឋានរបស់ប្រព័ន្ធធារាសាស្ត្រទេ ។

សហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUCs) ដែលមានព័ត៌មានគ្រប់គ្រាន់ និងការងារល្អ អាចធ្វើអោយសភាពការណ៍ប្រសើរឡើងយ៉ាងច្រើន ។ នៅតំបន់សិក្សាខ្លះ ក្រុមស្រាវជ្រាវបានពិនិត្យឃើញភស្តុតាងល្អៗនៃការត្រួតពិនិត្យពីសំណាក់ក្រុមអ្នកប្រើប្រាស់ ក្នុងមូលមូលដ្ឋាន ។

- ក្រុមអ្នកប្រើប្រាស់ផ្ទាល់ រឺថ្នាក់ភូមិ បានជួយដោះស្រាយទំនាស់ផ្សេងៗ ។ យើងមិនបានលឺពីការចូលរួមណាមួយរបស់ឃុំ រឺអ្នកខាងក្រៅទេ។
- ថ្លៃប្រើប្រាស់ទឹក ត្រូវបានលើកមកចរចាដោយចំហ និងគិតគូរថ្លឹងថ្លែងជាមួយគ្នា ។ សំណួមពរផ្សេងៗពីអ្នកប្រើប្រាស់ ឱ្យបញ្ចុះថ្លៃទឹកនៅពេលទឹកមានមិនគ្រប់គ្រាន់សំរាប់បំពេញតំរូវការ បានទទួលការយល់ព្រមហើយ ។ ថ្លៃទឹកមិនប្រមូលយកទេ នៅពេលផលដំណាំត្រូវខូចខាតដោយសារការរាំងស្ងួតខ្លាំង ។
- ប្រព័ន្ធវាស់វែងក្នុងមូលដ្ឋាន បានយកមកប្រើប្រាស់ដើម្បីគណនាថ្លៃប្រើប្រាស់ទឹក។ នៅពេលយើងសួរថា ត្រូវអស់ប៉ុន្មានក្នុងមួយហិកតា ពួកគេមិនដឹងទេ ពីព្រោះពួកគេបានប្រើរង្វាស់ក្នុងមូលដ្ឋាន ហើយរឿងនេះបង្ហាញច្បាស់ពីការត្រួតពិនិត្យក្នុងមូលដ្ឋាន និងការយល់ដឹងដ៏ជាក់លាក់របស់ប្រជាជនមូលដ្ឋាន ។ បញ្ហាអ្នកប្រើប្រាស់ទឹកដោយគ្មានការអនុញ្ញាតមិនចោទខ្លាំងទេៈ មានមនុស្សមួយចំនួននៅខាងក្រៅរង្វង់ព្រំដែនត្រូវទទួលការស្រោចស្រព បានធ្វើការបូមយកទឹកឆ្លងកាត់ដីរបស់អ្នកផ្សេងទៀត ប៉ុន្តែរឿងនេះយើងពុំឃើញមានការត្អូញត្អែរខ្លាំងទេ ។
- ទីដ្ឋភាពមួយចំនួននៃការគ្រប់គ្រងការស្រោចស្រព កំពុងដាក់ស្នើឡើងនៅក្នុងដំណើរការធ្វើផែនការឃុំ នៃកម្មវិធីសិលា ។
- ជាទូទៅ ការស្រោចស្រពជួយផ្ដល់ឱកាសរកចំណូលតូចៗថ្មីទៀតមួយចំនួន ដោយពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី និងបង្កើនផលប្រយោជន៍របស់ពួកគាត់ នៅក្នុងដំណើរការ FWUC ។ ចំនុចនេះក៏ជួយពង្រឹងការគ្រប់គ្រងនៅក្នុងមូលដ្ឋានដែរ ។

ជាការមានប្រយោជន៍ដែរ បើបានពិនិត្យពិចារណាពីបែបបទ ដែលគំរោងទាំងនេះផ្សារភ្ជាប់ជាមួយដំណើរការធ្វើផែនការឃុំ និងដំណើរការធ្វើផែនការខេត្ត ។ ដំណើរការទាំងពីរ គ្រប់ដណ្ដប់មិនបានគ្រប់គ្រាន់ទេ ប៉ុន្តែវាអាចជួយបំពេញបន្ថែមខ្លះៗដែរ ដល់គំរោងដែលមានការរចនារៀបចំ និងអនុវត្តល្អ ។ បើសិនគំរោងអនុវត្តមិនបានល្អ ដំណើរការធ្វើផែនការទាំងពីរ ក៏គ្មានប្រយោជន៍អ្វីដែរ។ ដំណើរការធ្វើផែនការឃុំអាចបន្ថែមប្រឡាយតូចៗ និងផ្ដល់តំហែទាំខ្លះៗ ប៉ុន្តែមិនអាចដោះស្រាយបញ្ហាធំៗបានទេ ។ ក្នុងផ្នែកធនធានទឹក ការធ្វើផែនការវាជាប់ពាក់ព័ន្ធនឹងមន្ទីរជំនាញជាច្រើន ហើយមិនសូវមានកំលាំងបញ្ជាទេ ពីព្រោះមិនអាចត្រួតត្រាលើអ្វីដែលកើតឡើងជាមួយគំរោង រឺក៏នៅពេលថ្នាក់មជ្ឈឹមមកក្ដោបក្ដាប់លើផលប្រយោជន៍ជាច្រើន ។ នៅពេលមានអនុវត្តគំរោងធំមួយក្នុងទឹកដីខ្លួន ខេត្តចំណេញបានតិចតួចណាស់ជាការកសាងសមត្ថភាព និងសិទ្ធិអំណាចត្រួតត្រា ប៉ុន្តែត្រូវទទួលបន្ទុកថែរក្សាអ្វីៗជាច្រើនដែលកំពុងតែដំណើរការ ។

## កំណត់សំគាល់

១. ប្រជាជនថ្មី គឺអ្នកពួកដែលរស់នៅទីក្រុង ខាងក្រៅតំបន់គ្រប់គ្រងរបស់ខ្មែរក្រហម មុនឆ្នាំ១៩៧៥។

២. ឯកឧត្តម វេង សាខុន សហប្រធាននៃក្រុមការងារខាងកសិកម្ម និងទឹក (TWGAW) និងជារដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម បានធ្វើរបាយការណ៍ជឿនលឿនការងារមួយស្ដីពី ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាថ្ងៃទី១៩-២០ មិថុនា ២០០៧ (www.cdc.crdb.gov.kh/cdc/first_cdcf/session1/progress_report_vengsakhon.htm)

## ឯកសារយោង


Chandler, D. (1993), *Tragedy of Cambodian History: Politics, War and Revolution*

*Since 1945* (London: Yale University Press)

Vickery, M. (1998), *Society, Economics, and Politics in Pre-Angkor Cambodia: the 7th–8th Centuries* (Tokyo: Centre for East Asian Cultural Studies)

Ojendal, J. (2000), *Sharing the Good: Modes of Managing Water Resources in the Lower Mekong River Basin* (Goteborg: Department of Peace and Development Research, Goteborg University)

Sakhon Veng (2007), *Irrigation Development and Management: A Presentation on the Occasion of the First Cambodian Development Cooperation Forum at the Council for the Development of Cambodia (CDC) from 19th to 20th June 2007,* (Phnom Penh: Ministry of Water Resources and Meteorology)

# ការទិញលក់ដីធ្លី និងបញ្ហាផុសឡើងក្រោយពេលចាប់ផ្ដើមចុះបញ្ជីដីធ្លី

*គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ក្នុងកិច្ចសហការជាមួយ មជ្ឈមណ្ឌលព័ត៌មានដីធ្លី (LIC) នៃវេទិកាអង្គការក្រៅរដ្ឋាភិបាលស្ដីពីកម្ពុជា បានធ្វើអង្កេតពីការទិញលក់ដី និងបញ្ហាផុសឡើងតាំងពីពេលចាប់ផ្ដើមចុះបញ្ជីដីធ្លីនៅសង្កាត់ចំនួនពីរនៃខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ**

## សេចក្ដីផ្ដើម

ក្រោយពីការអនុមតិច្បាប់ភូមិបាលនៅឆ្នាំ២០០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្ដួចផ្ដើមអនុវត្ត គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) នៅឆ្នាំ២០០២ ។ LMAP មានបំណងអភិវឌ្ឍសុវត្ថិភាពប័ណ្ណកម្មសិទ្ធិដី ពង្រឹងប្រព័ន្ធរដ្ឋបាលដីធ្លី និងជំរុញការអភិវឌ្ឍទីផ្សារដីធ្លីអោយកាន់តែមានប្រសិទ្ធភាព ។ ក្រោមការឧបត្ថម្ភពីធនាគារពិភពលោក GTZ (ទីភ្នាក់ងារអាល្លឺម៉ង់សំរាប់កិច្ចសហប្រតិបត្តិការបច្ចេកវិទ្យា) និង FINNMAP (ក្រុមហ៊ុនឯកជនហ្វាំងឡង់ ដែលរដ្ឋាភិបាលហ្វាំងឡង់បានចុះកិច្ចសន្យាជួល) LMAP បានជួយទ្រទ្រង់ដល់កម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ នៅខែកញ្ញា ឆ្នាំ២០០៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាយការណ៍ថា បានចេញរួចហើយនូវប័ណ្ណកម្មសិទ្ធិដីចំនួន ១លានប័ណ្ណ តាមរយៈ LMAP ។[១] អត្ថបទនេះពិនិត្យពីការទិញលក់ដី និងបញ្ហាផុសឡើងក្រោយពេលចាប់ផ្ដើមចុះបញ្ជីដីធ្លីក្នុងសង្កាត់[២] ចំនួនពីរនៃខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាពិសេសបញ្ហាភាពជាម្ចាស់ដី ការលក់ដី ដំណើរការផ្ទេរកម្មសិទ្ធិដី លទ្ធភាពទទួលបានឥណទាន និងសុវត្ថិភាពកាន់កាប់ដី ។

កម្មវិធីចុះបញ្ជីដីធ្លី ផ្អែកលើការសន្មតថា កម្មសិទ្ធិល្អប្រសើរលើដីធ្លីវាជះឥទ្ធិពលវិជ្ជមានលើការប្រើប្រាស់ និងផលិតភាពនៃទ្រព្យទាំងនោះ ។ គំរោងអង្កេតជាមូលដ្ឋាន LMAP តាមតំបន់ជនបទដែលធ្វើឡើងដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ក្នុងឆ្នាំ២០០៤ ផ្អែកលើសម្មតិកម្មសំខាន់ៗមួយចំនួនដូចជា ១) ទីផ្សារដីធ្លីៈ នៅពេលតំលៃដីកើនឡើង ហើយតំលៃដំណើរការទិញលក់ដីថយចុះ ទីផ្សារដីធ្លីនឹងបង្វែរដីធ្លីទៅរកការប្រើប្រាស់ ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ ២) រដ្ឋបាលដីធ្លីៈ ចំនួនភាគរយកាន់តែច្រើននៃប្រតិបត្តិការផ្ទេរដីធ្លីដូចជា ការលក់ និងការបន្តមរតក នឹងដំណើរការតាមរយៈការចុះបញ្ជីជាផ្លូវការ ។ ៣) លទ្ធភាពទទួលបានឥណទានៈ ប្រជាជននឹង ប្រើប័ណ្ណកម្មសិទ្ធិដីសំរាប់ដាក់ធានា ដើម្បីទទួលបានឥណទានពីស្ថាប័នផ្ដល់កំចីផ្លូវការ ។ ៤) វិវាទៈ ប័ណ្ណកម្មសិទ្ធិដីមានសុវត្ថិភាព នឹងកាត់បន្ថយករិត និងភាពញឹកញាប់នៃវិវាទដីធ្លី (CDRI 2007) ។ ការស្រាវជ្រាវដែលបានធ្វើឡើងសំរាប់អត្ថបទនេះ ក៏មានការតំរង់ទិសពីក្របខ័ណ្ឌទ្រឹស្ដីជាទូទៅនេះដែរ ។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់កន្លែងសំរាប់ការសិក្សានេះ បានធ្វើឡើងនៅខែឧសភា និងខែមិថុនា ២០០៧ នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ ក្នុងខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ សង្កាត់ព្រៃនប់ស្ថិតនៅតាមដងផ្លូវជាតិលេខ៤ ខាងត្បូងទីប្រជុំជនខ័ណ្ឌព្រៃនប់ តាមផ្លូវទៅក្រុងព្រះសីហនុ ។ សង្កាត់ទឹកល្អក់ ស្ថិតនៅតាមដងផ្លូវជាតិលេខ៣ ខាងកើតទីប្រជុំជនខ័ណ្ឌព្រៃនប់ តាមផ្លូវទៅខេត្តកំពត ។ សង្កាត់ព្រៃនប់ទទួលរងឥទ្ធិពលពីកំណើនសេដ្ឋកិច្ចនៅតាមដងផ្លូវជាតិលេខ៤ ប៉ុន្ដែសង្កាត់ទឹកល្អក់ ស្ថិតនៅដាច់ស្រយាលរហូតដល់ពេលមានការជួសជុលផ្លូវជាតិលេខ៣ ក្នុងសហសវត្សរ៍ថ្មីប៉ុណ្ណោះ ។

ការស្រាវជ្រាវនេះ ប្រើវិធីសាស្ត្របែបគុណភាព និងបរិមាណ ហើយបានចុះអង្កេតសរុប ១៣០គ្រួសារ នៅសង្កាត់ព្រៃនប់ ក្នុងភូមិព្រៃនប់២ និងភូមិបត់សិរមាន់ និង ១៣៤គ្រួសារទៀត នៅសង្កាត់ទឹកល្អក់ ក្នុងភូមិទួល និងភូមិកំពង់ស្វាច់តូច ។[៣] អង្កេតមានមុខសញ្ញាបានអនុវត្តលើគ្រួសារណា ដែលថ្មីៗនេះមានដីកសិកម្មមួយឡូតិ៍យ៉ាងតិចត្រូវបានចុះបញ្ជីដោយ LMAP ។ បន្ថែមពីលើបញ្ជីសំណួរ អង្កេតបានធ្វើសំភាសន៍ជាមួយក្រុមស្នូលដែលមានសមាសភាពជាអ្នកភូមិមកពីតំបន់ស្រាវជ្រាវទាំងបួន ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះដែលជាអ្នកលក់ដី និងអ្នកទិញដីបានជ្រើសរើសមួយចំនួននៅក្នុងភូមិ និងជាមួយបុគ្គលិកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅភ្នំពេញ និងក្រុងព្រះសីហនុ ។

## កម្មសិទ្ធិក្បាលដីកសិកម្មចុះបញ្ជីដោយ LMAP[៤]

នៅសង្កាត់ព្រៃនប់ ៩១% នៃក្បាលដីកសិកម្មទាំងអស់ដែលកាន់កាប់ដោយគ្រួសារធ្វើអង្កេត បានទទួលប័ណ្ណកម្មសិទ្ធិពី LMAP រីឯនៅសង្កាត់ទឹកល្អក់ គឺមាន ៩៣% ។ ដោយអ្នកកាន់កាប់ដីធំៗក្នុងសង្កាត់ទាំងពីរ មានកាន់កាន់ដីកសិកម្មច្រើនលើសលុប ដូច្នេះ ពួកគេទទួលប្រយោជន៍ពីការចុះបញ្ជីដីធ្លីបានច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ ឧទាហរណ៍ នៅសង្កាត់ព្រៃនប់ គ្រួសារជាម្ចាស់ដីកសិកម្មចាប់ពីមួយហិកតាឡើងទៅដែលចុះបញ្ជីដោយ LMAP តំណាងឱ្យ ៥៤% នៃគំរូតាង ប៉ុន្ដែកាន់កាប់ដល់ទៅ ៨៣% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ដូចគ្នាដែរ គ្រួសារនៅសង្កាត់ព្រៃនប់ ជាម្ចាស់ដីកសិកម្មចាប់ពីពីរហិកតាឡើងទៅដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ២០% នៃគំរូតាង ប៉ុន្ដែកាន់កាប់ដល់ទៅ ៥៤% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ទន្ទឹមគ្នានេះ បើធៀបចំណាត់ថ្នាក់កាន់កាប់ដីពីដីតិចទៅដីច្រើន គេឃើញថាទាំងចំនួន និងទំហំក្បាលដីកាន់កាប់ដែលចុះបញ្ជីដោយ LMAP នៅសង្កាត់ព្រៃនប់ បានកើនឡើង ។

---

* អត្ថបទនេះ ផ្អែកលើការសិក្សាធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ២០០៧ ដែលជាផ្នែកមួយនៃវគ្គសិក្សាស៊ីជំរៅរបស់ ADI ។ អ្នកស្រាវជ្រាវ បានចូលរួមមានជាអាទិ លោក ដួង វីរ័ត្ន និងអ្នកស្រី ឆាយ ពិដោរ (វបសអ) លោក ស្រេង ភិរម្យ និង ចាន់ សារិន (DPA) លោក ថាវ គឹមសាន និង ទូច សេដ្ឋា (លីកាដូ) លោក ម៉េច សុខន និង ខាន់ ចន្ថារ៉ូ (NGO Forum) លោក នួន បូរិន (LWF) លោក លុយ ប៊ុនថន (SCA) លោក កង សុវណ្ណា (ពន្លឺកុមារ) លោក ហ៊ត សីលា (VI) លោក សេង វក (HRVC) លោក ឡុក វិចិត្រ (CHED) លោក ង៉ែ រ៉េត (ក្រុមអភិវឌ្ឍន៍ភូមិ) និង លោក សាន ជ័យ (KIND) ។ អ្នកស្រាវជ្រាវជាសមាជិកក្រុម គឺមាន លោក ហែប សុខាន់ណារ៉ូ និង Megan MacInnes (LIC/NGO Forum) និង លោក គុង សៀកលី, អឿ អ៊ុល, ជុំ ស៊ីរ៉ុម, ឃួន ចាន់ឌ៉ុរ និង John McAndrew (ADI/CCC) ។

*តារាង១ : សង្ខេបដីមានប័ណ្ណ LMAP ដែលបានលក់ (ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧) សង្កាត់ព្រៃនប់ និង សង្កាត់ទឹកល្អក់ ខែឧសភា-មិថុនា ២០០៧*

| | សង្កាត់ព្រៃនប់ | | សង្កាត់ទឹកល្អក់ | | សរុប |
|---|---|---|---|---|---|
| | ចំនួន | %នៃចំនួនសរុប | ចំនួន | %នៃចំនួនសរុប | ចំនួន |
| ក្បាលដី LMAP បានលក់ | ៣៧ក្បាលដី | ៦៣ | ២២ក្បាលដី | ៣៧ | ៥៩ក្បាលដី |
| ទំហំដី LMAP បានលក់ | ១២,៣៦ហ.ត | ៧៤ | ៤,២៤ហ.ត | ២៦ | ១៦,៦ហ.ត |
| ផ្ទៃមធ្យមនៃដី LMAP បានលក់ | ០,៣៣ហ.ត | | ០,១៩ហ.ត | | ០,២៨ហ.ត |
| គ្រួសារបានលក់ដី LMAP | ២៤គ្រួសារ | ៥៥ | ២០គ្រួសារ | ៤៥ | ៤៤គ្រួសារ |

នៅសង្កាត់ទឹកល្អក់ អ្នកកាន់កាន់ដីធំៗដែលកាន់កាប់ដីកសិកម្មច្រើនលើសលុបដែរ គឺទទួលបានផលប្រយោជន៍ពីការចុះបញ្ជីដីធ្លី ច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ ឧទាហរណ៍ គ្រួសារនៅសង្កាត់ទឹកល្អក់ ជាម្ចាស់ដីកសិកម្មចាប់ពីមួយហិកតាឡើងទៅ ដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ៣៨% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៦៩% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ដូចគ្នាដែរ គ្រួសារនៅសង្កាត់ទឹកល្អក់ ជាម្ចាស់ដីកសិកម្មចាប់ពីពីរហិកតាឡើងទៅ ដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ១០% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៣៣% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ទន្ទឹមគ្នានេះ បើធៀបចំណាត់ថ្នាក់កាន់កាប់ដីពីតិចទៅច្រើន គេឃើញថា ទាំងចំនួន និងទំហំក្បាលដីកាន់កាប់ចុះបញ្ជីដោយ LMAP នៅសង្កាត់ទឹកល្អក់ បានកើនឡើងលើកលែងតែក្នុងមួយករណីប៉ុណ្ណោះ ។

## ការលក់ដីពីឆ្នាំ១៩៨៩ ដល់ពាក់កណ្តាលឆ្នាំ២០០៧

ការលក់ដីរបស់អ្នកឆ្លើយសំភាសន៍ក្នុងសង្កាត់ទាំងពីរ ក្នុងរយៈ៤ឆ្នាំកន្លះក្រោយពេលចាប់អនុវត្តគំរោង LMAP មានច្រើនជាងក្នុងរយៈ ១៤ឆ្នាំមុននោះបូកបញ្ចូលគ្នា ។ ចាប់ពីឆ្នាំ១៩៨៩ (ព្រមទាំងឆ្នាំមុនៗនោះទៀត) រហូតមកដល់ឆ្នាំ២០០២ មានការលក់ ៥៦ក្បាលដី ដោយ ៣៤គ្រួសារ នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ ។ ជាការប្រៀបធៀបចាប់ពីការផ្តល់ប័ណ្ណ LMAP នៅឆ្នាំ២០០៣ រហូតមកដល់ពេលស្រាវជ្រាវនាពាក់កណ្តាលឆ្នាំ២០០៧ មានការលក់ ៦៦ក្បាលដី ដោយ ៥១គ្រួសារនៅសង្កាត់ទាំងពីរ ហើយក្រោយមកមានការលក់ ៥៩ក្បាលដីមានប័ណ្ណ LMAP និង ៧ក្បាលដីទៀតគ្មានប័ណ្ណ LMAP ។ កំណើនយ៉ាងខ្លាំងនៃការលក់ដីរបស់អ្នកឆ្លើយសំភាសន៍នៅសង្កាត់ទាំងពីរ អាចមើលឃើញយ៉ាងច្បាស់ក្នុងឆ្នាំ២០០៦ ដែលបង្ហាញថា ទីផ្សារដីធ្លីបានរឹងមាំឡើង និងរីកធំជាខ្លាំង (ក្រាហ្វិក១) ។

ជាសរុប មកដល់ឆ្នាំ២០០៦ ការលក់ដីក្នុងគំរូតាងនៅសង្កាត់ព្រៃនប់មានចំនួនស្មើគ្នា រឺច្រើនជាងក្នុងគំរូតាងនៅសង្កាត់ទឹកល្អក់ លើកលែងតែនៅឆ្នាំ១៩៩៦ ។ នៅមុនពេលអនុវត្ត LMAP (ពីឆ្នាំ១៩៨៩ ដល់ ២០០២) ៨៦% នៃក្បាលដីបានលក់ទាំងអស់ គឺលក់ដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ ។ ក្នុងអំឡុងពេល LMAP (ពីឆ្នាំ២០០៣ ដល់ពេលចុះស្រាវជ្រាវនៅពាក់កណ្តាលឆ្នាំ២០០៧) អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់បានលក់ ៦១% នៃក្បាលដីបានលក់សរុប ។ ទោះបីគំលាតដ៏ធំនៃចំនួនលក់ដីរវាងអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទាំងពីរបានរួមតូចវិញបន្ទាប់ពីការធ្វើប័ណ្ណ LMAP ក្តី ក៏ទិន្នន័យទាំងនេះ បង្ហាញថា ការលក់ដីនៅតែមានកំរិតខ្ពស់ជាងក្នុងចំណោមអ្នកឆ្លើយសំភាសន៍ក្នុងអំឡុងពេល LMAP នៅសង្កាត់ព្រៃនប់ដដែល ។ គួរកត់សំគាល់ថា អ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ បានលក់ ៦០% នៃក្បាលដីបានលក់សរុប នៅឆមាសទី១ ឆ្នាំ២០០៧ ។ តួលេខនេះបង្ហាញថា

*ក្រាហ្វិក១ : ក្បាលដីលក់ដោយអ្នកឆ្លើយសំភាសន៍ក្នុងសង្កាត់ព្រៃនប់ និង ទឹកល្អក់ ពីឆ្នាំ១៩៨៩ ដល់ពាក់កណ្តាលឆ្នាំ២០០៧*



ក្នុងឆ្នាំ២០០៧ ការលក់ដីអនុវត្តដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ អាចមានច្រើនជាងការលក់ដីរបស់អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ ។ នៅមុនពេល និងក្រោយពេលអនុវត្ត LMAP អ្នកទិញយកដីដែលលក់ចេញដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ គឺជាអ្នករស់នៅក្នុងភូមិជាមួយពួកគាត់ ។

## ការលក់ដីមានប័ណ្ណ LMAP ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧

ចាប់តាំងពីមានការចេញប័ណ្ណកម្មសិទ្ធិនៅឆ្នាំ២០០៣ ១៧% នៃគ្រួសារឆ្លើយសំភាសន៍បានលក់ក្បាលដីមានប័ណ្ណ LMAP ។ ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧ នៅសង្កាត់ព្រៃនប់មាន ២៤គ្រួសារ រឺ ១៨% នៃគ្រួសារឆ្លើយសំភាសន៍ ដែលបានលក់ដីមានប័ណ្ណ LMAP ប៉ុន្តែនៅសង្កាត់ទឹកល្អក់ មានត្រឹមតែ ២០គ្រួសារ រឺ ១៥% នៃគ្រួសារឆ្លើយសំភាសន៍ប៉ុណ្ណោះ។ ទោះយ៉ាងណាតួលេខប្រហាក់ប្រហែលគ្នានៃចំនួនគ្រួសារអ្នកលក់ដី ហាក់បដិសេធនូវការពិតជាក់ស្តែងដែលថា អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ បានលក់ដីមានប័ណ្ណ LMAP ច្រើនជាងអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ខ្លាំងណាស់ ទោះគិតជាផ្ទៃដី រឺគិតជាចំនួនក្បាលដីក្តី (តារាង ១) ។

បើធៀបនឹងឆ្នាំ១៩៨៩ ដល់ ២០០២ តំលៃដីក្នុងអំឡុងពេល LMAP (២០០៣ ដល់ ពាក់កណ្តាលឆ្នាំ២០០៧) កើនឡើងខ្លាំងណាស់នៅ ៣ភូមិ ក្នុងចំណោម ៤ភូមិគំរូតាង ។ ក្រោយពេលធ្វើ LMAP តំលៃដីជាមធ្យមក្នុងមួយហិកតា ដែលបានលក់នៅសង្កាត់ព្រៃនប់ ក្នុងភូមិព្រៃនប់២ នឹងភូមិបត់សិរមាន់ កើនឡើង ៣២៣% និង ១៩% ។ ដូចគ្នាដែរ នៅសង្កាត់ទឹកល្អក់ក្នុងភូមិទួល និងភូមិកំពង់ស្នាច់តូច វាកើនឡើង ២៣១៣% និង ៤៤៨% ។ម្យ៉ាងទៀត អ្នកទិញមកពីក្រុងព្រះសីហនុ និងភ្នំពេញ កើនឡើងជាង ៥០% នៅអំឡុងពេល LMAP ។ តាមសំដីរៀបរាប់របស់អ្នកភូមិ អ្នកទិញដែលមកពីក្រៅសង្កាត់ទាំងពីរ ចូលចិត្តទិញក្បាលដីទាំងឡាយណាដែលមានប័ណ្ណ LMAP ។

## ហេតុផលនៃការលក់ដី នៅមុនពេល និងក្រោយពេល LMAP

ហេតុផលធំបំផុតដែលធ្វើអោយគ្រួសារនៅសង្កាត់ព្រៃនប់ និងទឹកល្អក់ លក់ដីធ្លីទាំងមុនពេល និងក្រោយពេលធ្វើ LMAP គឺដើម្បីចំណាយព្យាបាលជំងឺ (ក្រាហ្វិក២) ។ នៅមុនពេលធ្វើ LMAP (១៩៨៩-២០០២) ៤៨% នៃក្បាលដីដែលបានលក់ គឺដើម្បីបានប្រាក់ព្យាបាលជំងឺ ។ ដូចគ្នាដែរ ក្រោយពេលធ្វើ LMAP (២០០៣-ពាក់កណ្តាលឆ្នាំ២០០៧) ៤៦% នៃក្បាលដីដែលបានលក់ គឺដើម្បីបង់ថ្លៃព្យាបាលជំងឺ ។ ចំនួនដងនៃការលក់ដីដើម្បីទិញម្ហូបអាហារ បង្កើតរបររកស៊ីផ្សេងៗ និងសំរាប់បុណ្យទាន (មង្គលការ, បុណ្យសព...) គឺមានប្រហាក់ប្រហែលគ្នាក្នុងអំឡុងពេលទាំងពីរ ។ ផ្ទុយទៅវិញ នៅមុនពេលធ្វើ LMAP អ្នកឆ្លើយសំភាសន៍ភាគច្រើនបានលក់ដីដើម្បីទិញដីនៅកន្លែងផ្សេង ប៉ុន្តែក្រោយពេលធ្វើ LMAP អ្នកឆ្លើយសំភាសន៍ភាគច្រើនបានលក់ដីដើម្បីសងបំណុលគេ ។

## ដំណើរការផ្ទេរដី

អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ បានផ្ទេរសិទ្ធិកាន់កាប់ និងប័ណ្ណកម្មសិទ្ធិពីម្នាក់ទៅម្នាក់ តាមរយៈសាក្សី និងលិខិតបញ្ជាក់ ដែលឃើញមានប្រើនៅពាសពេញប្រទេសកម្ពុជា ។ នៅពេលខ្លះ ពុំមានការផ្លាស់ប្តូរលិខិតស្នាម រឺឯកសារបញ្ជាក់អ្វីទេ នៅពេលប្រគល់ប្រាក់ព្រមព្រៀងគ្នារវាងគូភាគីដែលជាទូទៅគឺជាសាច់ញាតិ អ្នកជិតខាង រឺ មិត្តភក្តិ ។[១០] គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលការលក់ដូរដីធ្លីភាគច្រើននៅមុនពេលធ្វើ LMAP បានធ្វើឡើងតាមរយៈកិច្ចសន្យាលក់ ដោយមានការបញ្ជាក់ពីកីរិតភូមិ រឺ ឃុំ ។ រឿងចំលែកបន្តិច គឺការធ្វើរបៀបរបបនេះបានបន្តអនុវត្តទៀតនៅក្រោយពេលធ្វើ LMAP ដោយសិទ្ធិកាន់កាប់ដីភាគច្រើនត្រូវបានផ្ទេរនៅត្រឹមកំរិតមូលដ្ឋាន ។ និន្នាការប្រហែលគ្នានេះ ក៏អាចពិនិត្យឃើញច្បាស់ដែរក្នុងការទិញដី (តារាង២) ។

LMAP មានបំណងបង្កើនការប្រើប្រាស់បញ្ជីគោលដីធ្លី ប៉ុន្តែបានវាយតំលៃខុសពីភាពរឹងមាំនៃទំនៀមទំលាប់ក្នុងសង្គម ។ ការអនុវត្តផ្ទេរដីដោយ

*ក្រាហ្វិក២ : មូលហេតុនាំឱ្យអ្នកឆ្លើយសំភាសន៍លក់ដី នៅមុនពេល និង ក្រោយពេលធ្វើ LMAP*



*តារាង២ : ដំណើរការផ្ទេរដីតាមរយៈការទិញ និង លក់ដី សង្កាត់ព្រៃនប់ និង សង្កាត់ទឹកល្អក់ ខែឧសភា-មិថុនា ២០០៧*

| | ក្បាលដីបានលក់មុនធ្វើ LMAP | | ក្បាលដីមានប័ណ្ណ LMAP បានលក់ | | ការទិញក្បាលដី | |
|---|---|---|---|---|---|---|
| ការផ្លាស់ប្តូរឈ្មោះម្ចាស់ | ចំនួន | % | ចំនួន | % | ចំនួន | % |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ភូមិ | 13 | 23 | 14 | 24 | 63 | 32 |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ឃុំ | 29 | 52 | 32 | 54 | 100 | 51 |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ស្រុក | 2 | 4 | --- | --- | --- | --- |
| ការផ្ទេរប័ណ្ណនៅការិយាល័យ LMAP សាលាក្រុងព្រះសីហនុ | --- | --- | 1 | 2 | --- | --- |
| ការធ្វើប័ណ្ណនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម ... ក្រុងភ្នំពេញ | --- | --- | --- | --- | 2 | 1 |
| ផ្សេងៗ | 12 | 21 | 12 | 20 | 29 | 15 |
| | សរុប=៥៦ ក្បាលដី | សរុប=៥៩ ក្បាលដី | សរុប=១៩៤ ក្បាលដី | | | |

មានលិខិតបញ្ជាក់ត្រឹមថ្នាក់ភូមិ និងឃុំ បានចាក់ឫសមាំណាស់ក្នុងសង្កាត់បានសិក្សាទាំងពីរ ។ នៅខែមិថុនា ២០០៧ កំណត់ត្រានៅការិយាល័យ LMAP សាលាក្រុងព្រះសីហនុ បង្ហាញថា ក្រោយពេលអនុវត្ត LMAP ក្នុងខ័ណ្ឌព្រៃនប់ទាំងមូល មានការផ្ទេរតែ ៩ក្បាលដី LMAP ប៉ុណ្ណោះដែលបានកត់ត្រាដោយការិយាល័យក្រុង ហើយឈ្មោះម្ចាស់ថ្មីបានកត់ត្រាស្របច្បាប់លើបញ្ជីគោលដីធ្លី ។ ចំពោះការធ្វើកិច្ចសន្យាលក់ត្រឹមថ្នាក់មូលដ្ឋាននេះ អ្នកឆ្លើយសំភាសន៍ ភាគច្រើនមានហេតុផលថា គ្មានការចាំបាច់អ្វីត្រូវធ្វើវែងឆ្ងាយថែមទៀតទេ ពីព្រោះពួកគេមានការជឿទុកចិត្តគ្នា រីឯហេតុផលចង់គេចវេសពីការបង់ពន្ធ កំរមានលើកឡើងណាស់ ។

## ឥណទាន

ដោយសារគំរូតាងសំរាប់ការសិក្សានេះបានជ្រើសរើសឡើង ដោយមានមុខសញ្ញាជាក់លាក់ ដូច្នេះទាំង ២៦៤គ្រួសារដែលឆ្លើយសំភាសន៍ សុទ្ធតែមានយ៉ាងហោចណាស់ដីមួយក្បាលដែលមានប័ណ្ណ LMAP ។ ដោយមូលហេតុនេះ វាគួរអោយចាប់អារម្មណ៍ខ្លាំងណាស់ ដែលការសិក្សាបានរកឃើញថា ៩៣% នៃគ្រួសារឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ និង ៩៤%នៃគ្រួសារឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ មិនដែលយកប័ណ្ណ LMAP ទៅដាក់ធានាដើម្បីខ្ចីប្រាក់ទាល់តែសោះ ។ រឿងនេះងាយយល់ទេ នៅពេលគេដឹងថា កំចីជាក្រុមផ្តល់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត គឺជាប្រភពប្រាក់កំចីចំបងគេរបស់អ្នកឆ្លើយសំភាសន៍ក្នុងសង្កាត់ទាំងពីរ ។ កំចីជាក្រុមរបស់អម្រឹតតំរូវឱ្យមានការធានាពីក្រុម និងភូមិ មិនមែនការដាក់ធានានូវទ្រព្យរបស់បុគ្គលម្នាក់ៗ ដូចជាប័ណ្ណកម្មសិទ្ធិដីនោះទេ ។

តាមការពិនិត្យឃើញ ទឹកប្រាក់ទទួលបានតាមរយៈកម្មវិធីកំចីជាក្រុមរបស់អម្រឹត គឺមានចំនួនគ្រប់គ្រាន់សំរាប់តំរូវការរបស់គ្រួសារឆ្លើយសំភាសន៍ក្នុងសង្កាត់ទាំងពីរ ។ កំចីជាបុគ្គលម្នាក់ៗពីអម្រឹត និងធនាគារអេស៊ីលីដា ដែលទូទៅមានទឹកប្រាក់ច្រើនៗ និងត្រូវមានវត្ថុដាក់ធានាដូចជាប័ណ្ណ LMAP ជាដើម កំរឃើញមានណាស់ក្នុងចំណោម គ្រួសារបានឆ្លើយសំភាសន៍ ។[១១] ដរាបណាកម្មវិធីកំចីជាក្រុមរបស់អម្រឹត នៅតែបន្តផ្គត់ផ្គង់បានតាមតំរូវការឥណទានរបស់អ្នកខ្ចីប្រាក់ក្នុងភូមិ ដរាបនោះប័ណ្ណកម្មសិទ្ធិដី LMAP នឹងមានតួនាទីតិចតួចប៉ុណ្ណោះក្នុងការបង្កើនលទ្ធបាពទទួលបានឥណទាន រឺ ផ្លាស់ប្តូររបៀបរបបស្វែងរកឥណទាននាបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ។

## សុវត្ថិភាពកាន់កាប់ដី

ជាទូទៅគ្រួសារឆ្លើយសំភាសន៍មានអារម្មណ៍ថា ពួកគេមានសុវត្ថិភាពខ្ពស់ជាងក្នុងការកាន់កាប់ដីកសិកម្មដែលមាន ប័ណ្ណ LMAP បើធៀបនឹងកាលពីមុនដែលមិនទាន់មានប័ណ្ណ ។ អ្នកឆ្លើយសំភាសន៍ដែលប្រាប់បែបនេះ មាន ៩១% នៅសង្កាត់ព្រៃនប់ និង ៩០% នៅសង្កាត់ទឹកល្អក់ ។[១២] ពួកគេបានផ្តល់ហេតុផលជាច្រើនពីអារម្មណ៍មានកំណើនសុវត្ថិភាពនេះ ដូចជា មានឈ្មោះរបស់ខ្លួនលើប័ណ្ណកម្មសិទ្ធិ មានការទទួលស្គាល់ប័ណ្ណកម្មសិទ្ធិក្នុងច្បាប់ភូមិបាល មានហត្ថលេខាមន្ត្រីសុរិយោដីនៅលើប័ណ្ណ និងមានការបញ្ជាក់ពីព្រំប្រទល់ និងវិវាទលើកម្មសិទ្ធិដី ។ ក្នុងចំណោមអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទាំងពីរ ដែលមានទាំងដីកសិកម្មមានប័ណ្ណ LMAP និងដីកសិកម្មគ្មានប័ណ្ណ LMAP ៩៧% បានឆ្លើយថា ក្បាលដីមានប័ណ្ណ LMAP មានសុវត្ថិភាពជាង ។

## សេចក្តីសន្និដ្ឋាន

នៅតំបន់សិក្សាក្នុងសង្កាត់ព្រៃនប់ និងទឹកល្អក់ ជាង ៩០% នៃក្បាលដីកសិកម្មទាំងអស់ដែលកាន់កាប់ដោយ គ្រួសារឆ្លើយសំភាសន៍នានា គឺទទួលបានប័ណ្ណពី LMAP ហើយនេះជាជោគជ័យមួយដ៏ធំ ។ ម្យ៉ាងទៀត វិសមភាពកាន់កាប់ដីក្នុងចំណោមអ្នកបានទទួលប័ណ្ណកម្មសិទ្ធិដី មានន័យថា អ្នកកាន់កាប់ដីធំៗនៅសង្កាត់ទាំងពីរដែល មានដីច្រើនលើសលប់ គឺបានទទួលផលប្រយោជន៍ពីការចុះបញ្ជីដីធ្លីច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ ដូច្នេះការផ្តល់ប័ណ្ណកម្មសិទ្ធិតាមគំរោង LMAP បានពង្រីងវិសមភាពកាន់កាប់ដី ព្រមគ្នានឹងការពង្រឹងសិទ្ធិលើទ្រព្យសម្បត្តិសំរាប់ប្រជាពលរដ្ឋគ្រប់រូបដែរ ។

ការលក់ដីនៅសង្កាត់ទាំងពីរ ក្នុងរយៈ៤ឆ្នាំកន្លះ ក្រោយពេលចាប់អនុវត្តគំរោង LMAP មានចំនួនច្រើនជាងក្នុងរយៈ ១៤ឆ្នាំមុននោះរួមគ្នាទាំងអស់ ។ ចំណុចនេះបង្ហាញថា ប័ណ្ណ LMAP បានជួយជំរុញឱ្យទីផ្សារដីធ្លីសកម្មឡើង ។

អ្នកទិញដែលរស់នៅក្នុងភូមិជាមួយអ្នកលក់ នៅតែមានច្រើនជាងគេ ទាំងនៅមុនពេល និងក្រោយពេលអនុវត្ត LMAP ប៉ុន្តែអ្នកទិញមកពីក្រុងព្រះសីហនុ និងក្រុងភ្នំពេញ បានកើនមួយជាពីរក្នុងអំឡុងពេល LMAP ។ ក្រោយការធ្វើប័ណ្ណ LMAP តំលៃដីក៏កើនឡើងខ្ពស់ណាស់ដែរសំរាប់ ៣ភូមិក្នុងចំណោមភូមិសិក្សាទាំង៤ ។ កំណើនតំលៃដីផ្តល់ផលចំណេញដល់អ្នកភូមិដែលលក់ដីក៏ពិតមែន ប៉ុន្តែគ្រួសារនានាតាមធម្មតាមិនមែនលក់ដីដើម្បីធ្វើវិនិយោគបង្កើនផលិតភាពនោះទេ ព្រោះជិត ៥០% នៃក្បាលដីដែលបានលក់ក្រោយពេលធ្វើ LMAP គឺដើម្បីយកប្រាក់ព្យាបាលជំងឺ ។ ដូច្នេះការលក់ដីនៅក្រោយពេលអនុវត្តគំរោង LMAP បានធ្វើឡើងជាសំខាន់ដើម្បីបានប្រាក់ប្រើប្រាស់នៅពេលជួបប្រទះគ្រោះអាសន្ន និងដោះស្រាយតំរូវការចិញ្ចឹមជីវិត ។

ក្រោយពេលធ្វើ LMAP ការលក់ដីភាគច្រើន នៅតែធ្វើឡើងក្រោមកិច្ចសន្យាលក់មានការបញ្ជាក់ពីថ្នាក់ភូមិ និងឃុំ ដោយគ្មានការផ្ទេរសិទ្ធិតាមការចុះបញ្ជីគោលដីធ្លីទេ ។ អ្នកភូមិភាគច្រើនគិតថា គ្មានការចាំបាច់អ្វីត្រូវធ្វើវែងឆ្ងាយថែមទៀតទេ ពីព្រោះពួកគេជឿទុកចិត្តគ្នាទៅវិញទៅមក ហើយជាទូទៅបទពិសោធន៍របស់ពួកគេនេះហុចលទ្ធផលល្អ ។ អ្នកទិញមកពីក្រៅភូមិ តាមធម្មតាមិនទាមទារការផ្ទេរសិទ្ធិតាមការចុះបញ្ជីគោលដីធ្លីថែមទៀតទេ ។ ដូចគ្នាដែរ នៅសង្កាត់ព្រៃនប់ ស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត និងធនាគារអេស៊ីលីដា ទទួលយកប័ណ្ណកម្មសិទ្ធិដី LMAP ព្រមជាមួយកិច្ចសន្យាលក់ និងលិខិតញ្ជាក់ធ្វើជាវត្ថុដាក់ធានាសំរាប់ការខ្ចីប្រាក់ ទោះបីជាប័ណ្ណទាំងនោះមិនបានឆ្លងកាត់ ការចុះបញ្ជីគោលដីធ្លីក៏ដោយ ។ ដូចនេះ បើសិនគ្មានការដាក់អនុវត្តតឹងរឹងនូវការតំរូវផ្សេងៗក្នុងច្បាប់ (ដែលប្រហែលជាពុំមានទេ) រឺក៏ការផ្លាស់ប្តូរនីតិវិធីសព្វថ្ងៃ របៀបរបបផ្ទេរកម្មសិទ្ធិដី "ក្រៅផ្លូវច្បាប់" នៅតែបន្តអនុវត្តទៀត ហើយនៅទីបំផុតនឹងគំរាមកំហែងដល់ជោគជ័យនៃកម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធតែម្តង។

ជាង ៩០% នៃគ្រួសារឆ្លើយសំភាសន៍ក្នុងសង្កាត់ទាំងពីរ មិនដែលយកប័ណ្ណកម្មសិទ្ធិដី LMAP ទៅដាក់ធានាដើម្បីសុំខ្ចីប្រាក់ទេ ។ ដរាបណាកម្មវិធីកំចីជាក្រុមរបស់អម្រឹត នៅតែបន្តដោះស្រាយបានតាមតំរូវការឥណទានរបស់អ្នកភូមិ ដរាបនោះប័ណ្ណកម្មសិទ្ធិដីដែលទទួលបានពី LMAP នៅតែមានតួនាទីតិចតួចក្នុងការបង្កើនលទ្ធភាពទទួលបានឥណទាន រឺការផ្លាស់ប្តូររបៀបរបបស្វែងរកឥណទានរបស់អ្នកភូមិនាបច្ចុប្បន្ន ។

ភាគច្រើនលើសលប់នៃគ្រួសារឆ្លើយសំភាសន៍បានប្រាប់ថា ផលប្រយោជន៍ចំបងដែលទទួលបានពី LMAP គឺសុវត្ថិភាពខ្ពស់ជាងមុនក្នុងការកាន់កាប់ដីមានប័ណ្ណកម្មសិទ្ធិ LMAP ។ អ្នកភូមិបានដឹងច្បាស់ពីសំពាធដែលពួកអ្នកទិញលក់ដីកេងយកចំណេញ និងអ្នកអភិវឌ្ឍន៍ដី អាចដាក់មកលើអ្នកភូមិ ហើយការមានប័ណ្ណកម្មសិទ្ធិក្នុងដៃវាផ្តល់ឧត្តមភាពមួយយ៉ាងធំ ។ ពិតមែនតែប័ណ្ណកម្មសិទ្ធិ LMAP មិនអាចជួយកាត់បន្ថយភាពក្រីក្របានភ្លាមៗសំរាប់អ្នកមានប័ណ្ណភាគច្រើនក្តី ក៏ប៉ុន្តែវាជាធាតុផ្សំមួយដ៏សំខាន់នៃកញ្ចប់អន្តរាគមន៍សំរាប់អភិវឌ្ឍន៍និងកំណែទំរង់ ដែលមានដូចជា ការផ្តល់គ្រប់គ្រាន់នូវសេវាថែទាំសុខភាពមានប្រសិទ្ធភាពល្អ និងតំលៃថោកសមរម្យ និងដែលអាចជួយរុញច្រានប្រជាពលរដ្ឋឱ្យចាកផុតពីភាពក្រីក្រ ហើយទទួលផលប្រយោជន៍បានកាន់តែស្មើភាពពីកំណើនសេដ្ឋកិច្ច ។

## កំណត់សំគាល់

១. អត្ថបទនេះប្រើពាក្យ "ប័ណ្ណ LMAP" សំរាប់ប័ណ្ណកម្មសិទ្ធិដីរបស់ខាងសុរិយោដី ដែលចេញឱ្យតាមគំរោង LMAP ។

២. សង្កាត់ គឺជាផ្នែករដ្ឋបាលមួយនៅក្នុងរាជធានី រឺទីក្រុង ដែលស្មើនឹងឃុំនៅតាមខេត្ត ។

៣. បញ្ជីសំនួរអង្កេតផ្អែកលើឧបករណ៍ ដែលបានប្រើក្នុងគំរោងអង្កេតជាមូលដ្ឋានរបស់ វិបសអ-CDRI (CDRI 2007) ។

៤. ទិន្នន័យ ក្រាហ្វិក និងតារាង ដែលបង្ហាញជូននៅក្នុងអត្ថបទនេះ បានមកពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)/វេទិកាអង្គការក្រៅរដ្ឋាភិបាលសំរាប់ការសិក្សាពីកម្ពុជា : *ការចុះបញ្ជីដីធ្លី និងការកាត់បន្ថយភាពក្រីក្រ: ការសិក្សានៅសង្កាត់ចំនួនពីរក្នុងខ័ណ្ឌព្រៃនប់ក្រុងព្រះសីហនុ,* ក្រុមវិភាគបញ្ហាអភិវឌ្ឍន៍ និងអ្នកចូលរួមស្រាវជ្រាវដោយរួមសហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី នៅខែវិច្ឆិកា ឆ្នាំ២០០៧ ។

៥. អ្នកកាន់កាប់ដីធំៗ ដែលមានដីកសិកម្មច្រើនលើសលុប ទទួលផលប្រយោជន៍ពីការធ្វើប័ណ្ណកម្មសិទ្ធិដី បានច្រើនជាងអ្នកកាន់កាន់ដីតូចៗតាមរយៈតំលៃបន្ថែមបានដល់ទ្រព្យ កំណើនរបស់ដាក់ធានាដើម្បីទទួលបានឥណទានផ្លូវការ និងសុវត្ថិភាពកាន់កាប់ផ្ទៃដីបានកាន់តែធំ ។

៦. ខណៈដែលការលក់ដីក្នុងអំឡុងពេល LMAP (២០០៣-ពាក់កណ្តាលឆ្នាំ២០០៧) មានចំនួនច្រើនជាងក្នុងអំឡុងពេលមុន LMAP (១៩៨៩-២០០២) គេគួរកត់ចំណាំថា ទំហំដីសរុបដែលបានលក់ក្នុងអំឡុងពេល LMAP (២០ហិកតា) វាតិចជាខ្លាំងជាងទំហំដីដែលបានលក់មុនពេល LMAP (៣០ហិកតា) ។

៧. ក្នុងផ្នែកនេះ និងផ្នែកបន្តបន្ទាប់ទៀត ការលើកឡើងពីក្បាលដីបានលក់ពីឆ្នាំ២០០៣ ដល់ ពាក់កណ្តាលឆ្នាំ២០០៧ មានរួមបញ្ចូលតែក្បាលដីមានប័ណ្ណ LMAP ដែលបានលក់ចំនួន ៥៩ក្បាលដីប៉ុណ្ណោះ ។ រីឯ ៧ក្បាលដីគ្មានប័ណ្ណ ដែលបានលក់អំឡុងពេលដូចគ្នា មិនបានគិតបញ្ចូលទេ ។

៨. តំលៃមធ្យមក្នុងមួយហិកតានៃក្បាលដីដែលបានលក់ នៅមុនពេលអនុវត្ត LMAP (១៩៨៩-២០០២) និងក្រោយអនុវត្ត LMAP (២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧) បានកើនឡើងនៅភូមិព្រៃនប់២ ពី ៤១៩ដុល្លារ ដល់ ១៧៧១ដុល្លារ ភូមិបត់សិរមាន់ ពី ១៦៣១ដុល្លារ ដល់ ១៩៤០ដុល្លារ ភូមិទួល ពី ២៩២ដុល្លារ ដល់ ៧០៤៧ដុល្លារ និងភូមិកំពង់ស្មាច់តូច ពី ១៦១ដុល្លារ ដល់ ៨៨៣ដុល្លារ ។

៩. CDRI (2004) រាយការណ៍ថា ការថែទាំសុខភាពជាមូលហេតុនាំអោយមានការលក់ក្បាលដីចំនួន ២៥% ក្នុងតំបន់គោលដៅ LMAP ពីឆ្នាំ ១៩៨៩ -២០០៤ ។

១០.ការផ្ទេរសិទ្ធិធ្វើឡើងដោយគ្មានលិខិតស្នាម រឺលិខិតបញ្ជាក់សំរាប់ចំលើយក្នុងខ្ទង់ "ផ្សេងៗ" នៃតារាង២ ។

១១.ទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត និងធនាគារអេស៊ីលីដា មានសាខានៅទីប្រជុំជនខ័ណ្ឌព្រៃនប់ ។

១២.CDRI (2007) រាយការណ៍ថា ៨០% នៃគ្រួសារឆ្លើយសំភាសន៍នៅតំបន់អនុវត្ត LMAP មានអារម្មណ៍ថា សុវត្ថិភាពកាន់កាប់ដី គឺជាផលប្រយោជន៍សំខាន់ជាងគេ ដែលទទួលបានពីការចុះបញ្ជីដីធ្លី ។

## ឯកសារយោង

វិបសអ-CDRI (2007), កម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា: របាយការណ៍អង្កេតមូលដ្ឋាននៅតំបន់ជនបទ (ភ្នំពេញ : វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

រៀងរាល់ត្រីមាស ទំព័រនេះគូសបញ្ជាក់ពីដំណើរការសេដ្ឋកិច្ចរបស់ប្រទេសមានសេដ្ឋកិច្ចខ្លាំងៗក្នុងពិភពលោក និងរបស់ប្រទេសភាគច្រើននៅអាស៊ីខាងកើត ។ ការវិវត្តសេដ្ឋកិច្ចនៅប្រទេសទាំងនោះ មានជាប់ទាក់ទងច្រើនណាស់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ។

ផសស ពិត របស់សហរដ្ឋអាមេរិក នៅត្រីមាសទី៣ ឆ្នាំ២០០៧ កើនឡើង ៤,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ កំណើននេះឆ្លុះបញ្ចាំងជាសំខាន់ពីការចូលរួមចំណែកជាវិជ្ជមាននៃការនាំចេញ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគលើស្តុកឯកជន បរិក្ខារ និង សូហ្វវែរ ចំណាយរដ្ឋាភិបាលសហព័ន្ធ ចំណូល-ចំណាយរបស់អនិវាសជន ព្រមទាំងចំណាយរបស់រដ្ឋាភិបាលនៅតាមរដ្ឋ និងនៅតាមមូលដ្ឋាន ។ ផសស ពិត នៅតំបន់អឺរ៉ូក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ២,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង កើន ០,៨% ធៀបនឹងត្រីមាសមុន។ ផសស ពិត នៅជប៉ុន កើន ១,៩% ធៀបនឹងឆ្នាំមុន និង កើន ០,៣% ធៀបនឹងត្រីមាសមុន ។

សេដ្ឋកិច្ចប្រទេសចិននៅត្រីមាសទី៣ ឆ្នាំ២០០៧ កើនឡើង ១១,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែវាមានកំណើនយឺតបន្តិច ធៀបនឹងត្រីមាសទី២ ។ រឿងនេះឆ្លុះបញ្ចាំងជាចំបងពីកំណើនយ៉ាងខ្លាំងក្នុងវិស័យឧស្សាហកម្ម សេវាកម្ម ការនាំចេញ និង វិនិយោគទុន ។ ផសស ពិតរបស់កូរ៉េខាងត្បូង នៅត្រីមាសទី៣ កើន ៥,២% ធៀបនឹងឆ្នាំមុន និង កើន ១,៣% ធៀបនឹងត្រីមាសមុន ។ កំណើនផលិតកម្ម និងសេវាកម្ម បានបង្កើន ល្បឿន រីឯកំណើនក្នុងវិស័យសំណង់បានថយល្បឿនមកវិញ ។ គិតតាមតួលេខចំណាយ ការនាំចេញទំនិញ បន្តមានអត្រាកំណើនខ្ពស់ កំណើនចំណាយប្រើប្រាស់ឯកជនកាន់តែស្ទុះលឿន រីឯវិនិយោគខាងសំណង់ និងបរិក្ខារមានការថយចុះ ។ ផសស ពិត នៅតៃវ៉ាន់ និង ហុងកុង ក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ៦,៩% និង ៦,២% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំមុន ។

នៅត្រីមាសទី៣ ឆ្នាំ២០០៧ សេដ្ឋកិច្ចម៉ាឡេស៊ុី កើន ៦,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ដំណើរការសេដ្ឋកិច្ចខ្លាំងក្លា បណ្តាលមកពីកំណើនសេវាកម្ម (១០,៥%) និង ផលិតកម្ម (៣,៤%)។ សេដ្ឋកិច្ចសិង្ហបុរី កើន ៨,៩% នៅត្រីមាសទី៣ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ វិស័យដែលកើនលឿនជាងគេគឺ ផលិតកម្ម (នាំមុខគេដោយជីវឱសថ និងវិស្វកម្មខាងដឹកជញ្ជូន) សេវាកម្មហិរញ្ញវត្ថុ និង សំណង់ ។ ផសស ពិត នៅថៃក្នុងត្រីមាសទី៣ ឆ្នាំ២០០៧ កើន ៤,៨% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ ២០០៦ ។ កសិកម្ម កើន ១,៧% គឺថយចុះពីកំណើន ៧,៥% នៅត្រីមាសមុន រីឯផលិតផលសំរេចមិនមែនកសិកម្ម កើន ៥,០% ធៀបនឹងកំណើន ៤,០% កាលពីត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និង អត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៣ ឆ្នាំ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិកកើន ២,៤% ធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារ កំណើនថ្លៃម្ហូបអាហារ ការថែទាំសុខភាព ផ្ទះ ការអប់រំ ទូរគមនាគមន៍ និង ថាមពល ។ នៅតំបន់អឺរ៉ូ អតិផរណាមានអត្រា ១,៩% គឺដូចគ្នានឹងកាលពីត្រីមាសមុន ។ ព័ត៌មានដែលទទួលបានវាបង្ហាញថា កត្តាថាមពល ហើយជាពិសេសការធៀបនឹងឆ្នាំមុនដែលមានការថយចុះតំលៃថាមពល បានរួមចំណែកបង្កើនតួលេខប៉ាន់ស្មានកំណើននៅត្រីមាសទី៣ ឆ្នាំ២០០៧ ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅជប៉ុន ធ្លាក់ចុះ ០,១% ធៀបនឹងឆ្នាំមុន ហើយវាបានធ្លាក់ចុះអស់បីត្រីមាសជាប់ៗគ្នាមកហើយ ។ រឿងនេះឆ្លុះបញ្ចាំងជាសំខាន់ពីការចុះថ្លៃខ្សែទស្សនកិច្ចទៅក្រៅប្រទេស និងបរិក្ខារអេឡិចត្រូនិកប្រើប្រាស់ក្នុងគ្រួសារ ។ ប៉ុន្តែអត្រានៃការប្រែប្រួលមានកំរិតទាបជិតស្មើសូន្យ ប្រសិនបើគេមិនគិតបញ្ចូលនូវថ្លៃផលិតផលប្រេងឥន្ធនៈ និងកត្តាពិសេសផ្សេងៗទៀតនោះទេ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៧ នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១១៧,៧យ៉េន/ដុល្លារUS គឺធ្លាក់ថ្លៃពី ១២០,៨យ៉េន/ដុល្លារUS នៅត្រីមាសទី២ ។ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងប្រាក់អឺរ៉ូ ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន ០,៧៣អឺរ៉ូ/ដុល្លារUS, ៧,៥៥យ៉ុន/ដុល្លារUS, និង ៩២៧វ៉ុន/ដុល្លារUS ធៀបនឹងត្រីមាសទី២ ដែលមានអត្រា ០,៧៤អឺរ៉ូ/ដុល្លារUS, ៧,៦៨យ៉ុន/ដុល្លារUS, និង ៩២៩វ៉ុន/ដុល្លារUS ។ ដុល្លារUS ធ្លាក់ថ្លៃដោយសារពួកពាណិជ្ជកររំពឹងថា ធនាគារកណ្តាលអាមេរិក នឹងបន្តកាត់បន្ថយអត្រាការប្រាក់ដើម្បីទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ច ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៧ ថ្លៃប្រេងឆា សណ្តែកសៀង អង្ករ ប្រេងឆៅ និង ម៉ាស៊ូត កើនឡើង រីឯថ្លៃពោត និង សាំង ធ្លាក់ចុះ។ ប្រេងឆា លក់បាន ៧៤៥,៨៦ដុល្លារUS/តោន ដែលកើនពី ៦៩១,៤៤ដុល្លារUS/តោន នៅត្រីមាសទី២ ខណៈពេលដែលពោត និង សណ្តែកសៀង លក់បាន ១៣៩,៨១ ដុល្លារUS/តោន និង ២៩៩,៩៩ដុល្លារUS/តោន ។ នៅទីផ្សារក្រុងបាងកក អង្ករ Thai 100% B លេខពីរ លក់ថ្លៃ ៣០៤,៧៥ដុល្លារUS/តោន ដែលកើនពី ២៨៣,៨៩ដុល្លារUS/តោន នៅត្រីមាសទី២ ។ ថ្លៃប្រេងឆៅ នៅត្រីមាសទី៣ កើន ១១% ធៀបនឹងត្រីមាសមុន ដល់ ៧២,៤៨ដុល្លារUS/ធុង ។ ថ្លៃសាំង ថយចុះ ៤,២% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៥,៤៩សេន/លីត្រ រីឯថ្លៃម៉ាស៊ូត កើន ៥,០% ដល់ ៥៥,៦២សេន/លីត្រ ។

*រៀបរៀងដោយ លោក ហ៊ីង វុត្ថា និង លោក ភីម រុនស៊ីណារិទ្ធិ*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

*តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.8 | 7 | 7.7 | 13.4 | 10.6 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.5 | 6.1 | - | - | - |
| ម៉ាឡេស៊ី | 5.6 | 5.4 | 7 | 5.2 | 5.9 | 5.8 | 5.7 | 5.3 | 5.7 | 6.7 |
| សិង្ហបុរី | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 7.1 | 7.0 | 6.0 | 8.2 | 8.9 |
| ថៃ | 6.1 | 6.9 | 6 | 4.5 | 4.8 | 4.7 | 4.2 | 4.3 | 4.4 | 4.8 |
| វៀតណាម | 6.7 | 7 | 7.5 | 8.4 | 8.1 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 10.4 | 10.7 | 11.1 | 11.5 | 11.4 |
| ហុងកុង | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 6.8 | 7.0 | 5.6 | 6.9 | 6.2 |
| កូរ៉េខាងត្បូង | 6.1 | 3 | 4.7 | 4.7 | 5.0 | 4.8 | 5.0 | 4.0 | 4.5 | 5.2 |
| តៃវ៉ាន់ | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 5.0 | 4.0 | 4.1 | 5.07 | 6.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.6 | 3.3 | 3.0 | 2.5 | 2.7 |
| ជប៉ុន | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.7 | 2.3 | 2.2 | 2.3 | 1.9 |
| សហរដ្ឋអាមេរិក | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.3 | 3.1 | 1.5 | 3.8 | 4.9 |

*Sources: International Monetary Fund, Economist and countries' statistic offices*

*តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 Q3 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.9 | 3.4 | 3.0 | 4.6 | - |
| ឥណ្ឌូនេស៊ី | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 14.9 | 6.1 | 6.4 | - | - |
| ម៉ាឡេស៊ី | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 3.6 | 3.1 | 2.6 | 1.4 | 1.8 |
| សិង្ហបុរី | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 0.7 | 0.6 | 0.5 | 1.0 | 2.7 |
| ថៃ | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 3.6 | 3.3 | 2.4 | 1.9 | 1.7 |
| វៀតណាម | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.8 | 2.6 | 3.6 | 6.1 |
| ហុងកុង | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.3 | 2.2 | 1.7 | 1.3 | 1.6 |
| កូរ៉េខាងត្បូង | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.4 | 2.0 | 2.4 | 2.3 |
| តៃវ៉ាន់ | -0.2 | -0.3 | 1.6 | 2.3 | 0.6 | -0.3 | -0.1 | 1.0 | 0.3 | 1.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | 0.0 | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.8 | 1.9 | 1.9 | 1.9 |
| ជប៉ុន | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.6 | 0.3 | -0.1 | -0.1 | -0.1 |
| សហរដ្ឋអាមេរិក | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 3.3 | 1.9 | 2.4 | 2.7 | 2.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

*តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4125.0 | 4111.3 | 4046.7 | - | - |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9311 | 8577 | 8938 | 9705 | 9134 | 9122 | 9125 | 9107 | - | - |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.67 | 3.62 | 3.50 | 3.43 | 3.46 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.58 | 1.56 | 1.53 | 1.52 | 1.52 |
| ថៃ (បាត) | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 37.7 | 36.5 | 33.9 | 32.5 | 31.4 |
| វៀតណាម (ដុង) | 15,280 | 15,510 | - | 15,859 | 15,994 | 16,015 | 16,077 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 7.97 | 7.86 | 7.76 | 7.68 | 7.55 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.78 | 7.78 | 7.81 | 7.82 | 7.81 |
| កូរ៉េខាងត្បូង (វ៉ុន) | 1251 | 1192 | 1145 | 1024 | 955 | 955 | 938 | 939 | 929 | 927 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.8 | 32.8 | 32.9 | 33.1 | 32.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 | 0.74 | 0.73 |
| ជប៉ុន (យ៉េន) | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 116.3 | 117.8 | 119.4 | 120.8 | 117.7 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

*តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - US ($/តោន) | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 108.67 | 140.18 | 154.33 | 146.10 | 139.81 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 446.85 | 494.92 | 552.06 | 691.44 | 745.86 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 289.91 | 279.10 | 294.17 | 283.89 | 304.75 |
| សណ្ដែកសៀង (US No. 1) – US ($/តោន) | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.38 | 230.17 | 255.33 | 259.95 | 299.99 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 67.00 | 56.39 | 54.21 | 65.41 | 72.48 |
| សាំង – US Gulf Coast (សេន/លីត្រ) | 19.1 | 23 | 30.9 | 42.19 | 47.70 | 52.70 | 41.02 | 41.71 | 57.93 | 55.49 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) – US Gulf Coast (សេន/លីត្រ) | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.66 | 46.11 | 45.61 | 53.90 | 56.62 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

*តទៅទំព័រទី ៥* **របាយការណ៍សង្ខេប...**

**កំណត់សំគាល់**

១. នៅឆ្នាំ២០០៥ ក្រសួងនេះ បានបែងចែកជា ក្រសួងការងារ (MLVT) និង ក្រសួងសង្គមកិច្ច យុទ្ធជន និងយុវនិតិសម្បទា (MOSAVY) ។

២. តួលេខ មានខ្ពស់ជាងនៅប្រទេសថៃ និងវៀតណាម ដែលមានការនាំពលករចេញយ៉ាងច្រើន ។ យោងតាម Dang (២០០៧) នៅវៀតណាម ក្រុមហ៊ុនជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណមិនតំរូវឱ្យដាក់ប្រាក់ដិកល់អ្វីទេ ។

៣. ព័ត៌មានបានមកពីកិច្ចប្រជុំជាមួយសមាជិករបស់បណ្ដាញ NGO ។

៤. ជំនួបជាមួយមន្ត្រីថៃនៅក្រសួងការងារ នៅថ្ងៃទី១៥ វិច្ឆិកា ២០០៧ ។

៥. កម្ពុជា បានសំរេចផ្លាស់ប្ដូរយ៉ាងរហ័សទៅប្រើប្រាស់លិខិតឆ្លងដែនទិន្នន័យអេឡិចត្រូនិក (ប្រហែលជាប្រទេសដំបូងនៅក្នុងតំបន់ដែលធ្វើរឿងនេះ) ដោយមិនបានគិតពីចំណាយដ៏លើសលប់ ។ ក្រុមការងារម៉ាឡេស៊ី ៦នាក់ ជាអ្នកដាក់បញ្ចូលបន្ទះទិន្នន័យ និងទទួលបានកំរៃ ២០ដុល្លារ សំរាប់លិខិតឆ្លងដែនមួយ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទីបី ២០០៧ វិនិយោគ សកម្មភាពសាងសង់ ទេសចរណ៍ និង ពាណិជ្ជកម្ម មានកំណើនវិជ្ជមាន ។ វិនិយោគកើនឡើងជាខ្លាំង ធៀបនឹងត្រីមាសមុន ហើយរួមចំណែកយ៉ាងច្រើនដល់ដល់កំណើនសេដ្ឋកិច្ច ។ ការអនុម័តគំរោងសាងសង់ និងចំនួនភ្ញៀវមកដល់ កើនឡើងតិចតួច ហើយ ឱនភាពពាណិជ្ជកម្មបានកែលំអគួរសមឡើងវិញ ។

នៅត្រីមាសទីបី អនុមតិគំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ សរុប (៣៧គំរោង) កើនដល់ ១១៥៦,៩លានដុល្លារ វីកើនជាមធ្យម មួយជាបួន ធៀបនឹងតំលៃនៅត្រីមាសដូចគ្នា ឆ្នាំ២០០៦។ គំរោងវិស័យឧស្សាហកម្មបានអនុម័ត កើន ០,៩% ដល់ ១៨៧,២លានដុល្លារ (២៥គំរោង) ដែលបានមកពីអនុវិស័យកាត់ដេរ ។ និន្នាការតាមរដូវនៃការអនុម័តគំរោងសំរាប់អនុវិស័យកាត់ដេរ បង្ហាញថា ត្រីមាសទីបី គឺជាអំឡុងពេលដែលវាតែងកើនឡើងជារៀងរាល់ឆ្នាំ ។ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់នៃអនុវិស័យកាត់ដេរ កើន ៧៦% ដល់ ៤០,៧លានដុល្លារ សំរាប់ ១១គំរោង ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ អនុមតិគំរោងវិនិយោគខាងរ៉ែ កើនមួយជាបួន ដល់ ១១,២លានដុល្លារ វីឯខាងថាមពលបានកើនពីសូន្យ ដល់ ៣,១លានដុល្លារ ។ ប្រសិនបើគំរោងអនុមតិខាងឧស្សាហកម្មទាំងអស់ អនុវត្តបានជាក់ស្តែង វានឹងបង្កើតបានសរុប ២៩,២០៨ការងារថ្មី ក្នុងនេះ ៧៣% ស្ថិតក្នុងអនុវិស័យកាត់ដេរ ។ វិនិយោគលើវិស័យកសិកម្មក៏កើនឡើងដែរតាំងពីកំរិតសូន្យនៅឆ្នាំមុន ទៅដល់ ១២,០លានដុល្លារ សំរាប់គំរោងកសិ-ឧស្សាហកម្មពីរ ដែលផ្តល់ការងារដល់កម្មករ ១០០០នាក់ ។ គំរោងវិស័យសេវាកម្មបានអនុម័ត កើនមួយជាដប់ធៀបនឹងឆ្នាំមុន ដល់ ៩៥៧,៧លានដុល្លារ (១០គំរោង)។ វីឯអនុមតិវិនិយោគលើវិស័យសេវាកម្មវិញ ខាងទេសចរណ៍មានដល់ ៦៨% និង ទូរគមនាគមន៏ ២៣% ហើយគំរោងទាំងនេះរំពឹងថា នឹងផ្តល់ការងារដល់កម្មករ ៨៧៦៧នាក់ ។

ការវិនិយោគកើតមាននៅតាមទីក្រុង ជាពិសេសក្រុងភ្នំពេញ ។ ដោយសារនៅទីក្រុង ចំនួនប្រជាជន និងអាជីវកម្មផ្សេងៗបន្តកើនឡើង ឥតឈប់ឈរ សកម្មភាពសាងសង់ក៏រីកដុះដាលទាំងការសាងសង់ថ្មី និង ការជួសជួលសំណង់មានស្រាប់ ហើយសេវាកម្មអចលនទ្រព្យក៏រីកលូតលាស់តាមនោះដែរ ។ សំណង់ផ្ទះល្វែងនៅក្នុងក្រុង និងជាយក្រុង មានសន្ទុះលឿនជាងសំណង់ឯទៀតៗ ។ នៅត្រីមាសទីបី ២០០៧ អនុមតិគំរោងសាងសង់ទាំងអស់នៅភ្នំពេញ កើន ២៤% ធៀបនឹងត្រីមាសមុន ដល់ ១៧៩,៧លានដុល្លារ ក្នុងនេះផ្ទះល្វែងមាន ៦៥% វីកើនឡើងមួយជាបី ធៀបនឹងត្រីមាសមុន ។ អនុមតិគំរោងសាងសង់ភូមិគ្រឹះនិងផ្ទះ មានចំនួន ២១,៧លានដុល្លារ វីថយចុះ ៤,៨% ហើយសំណង់ផ្សេងៗទៀត ធ្លាក់ចុះ ៥៤% មកត្រឹម ៤០,៦ លានដុល្លារ ។

ឱនភាពពាណិជ្ជកម្មមានកំរិត ៣០,៣លានដុល្លារ គឺប្រសើរជាងត្រីមាសមុនដែលមានទំហំដល់ ២០៨,១លានដុល្លារ ប៉ុន្តែនៅអន់ជាងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដែលមានអតិរេកដល់ ២៣,២លានដុល្លារ ។ ក្នុងអំឡុង ១២ខែនេះ ការនាំចេញ និងនាំចូលសរុប បានកើនឡើងបង្គួរ ។

នៅត្រីមាសទីបី ២០០៧ ការនាំចេញរបស់កម្ពុជា កើន ១០% ធៀបនឹងត្រីមាសទីបី ២០០៦ ដល់ ៨៩០,៨លានដុល្លារ ។ វិស័យកាត់ដេរជាកត្តាចំបងដែលបណ្តាលអោយមានកំណើននេះ ដោយវារួមចំនែក ៩៥% នៃការនាំចេញសរុប និងកើនបាន ៨,២% ធៀបនឹងឆ្នាំមុន ដល់ ៨៤៦,១លានដុល្លារ ។ ការនាំចេញឈើថយចុះ ៩៩% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ មកត្រឹម ០,០១លានដុល្លារ, ការនាំចេញត្រី ធ្លាក់ចុះ ២៧% មកត្រឹម ១,២លានដុល្លារ ហើយការនាំចេញកៅស៊ូ ធ្លាក់ចុះ ១៤% មកត្រឹម ១១,៧លានដុល្លារ ។ វិស័យកសិកម្មរួមចំនែកតិចតួចណាស់ដល់ការនាំចេញរបស់កម្ពុជា វីឯវិស័យកាត់ដេរវិញ វាជាស្នូលនៃកំណើនការនាំចេញ ហើយបានផ្តល់ការងារដល់កំលាំងពលកម្មមួយភាគធំ។ ប៉ុន្តែទីផ្សារកាត់ដេរកាន់តែមានការប្រកួតប្រជែងខ្លាំង ពីព្រោះប្រទេសមួយចំនួន ដូចជា ចិន និង វៀតណាម គេមានកំរិតតំលៃអាចប្រកួតប្រជែងបានច្រើនធៀបនឹងកម្ពុជា ដូចជា តំលៃពលកម្មជាដើម។

ផលិតកម្មក្នុងស្រុក មិនអាចផ្គត់ផ្គង់គ្រប់គ្រាន់តាមតំរូវការក្នុងស្រុកទេ ដូច្នេះការនាំចូលបន្តកើនឡើង ។ នៅត្រីមាសទីបី ២០០៧ ការនាំចូលសរុបមានតំលៃ ៩២៤,៥លានដុល្លារ វីកើន ១៨% ធៀបនឹងឆ្នាំមុន។ ការនាំចូលស៊ីម៉ង់ត៍ ដែក និងក្រណាត់ ធ្លាក់ចុះ ប៉ុន្តែការនាំចូលផលិតផលប្រេងកាតកើនឡើង ១៤% ដល់ ៧១,០លានដុល្លារ ។ ការនាំចូលស៊ីម៉ង់ត៍ធ្លាក់ចុះ ១០% មកត្រឹម ១៤,៣លានដុល្លារ, ការនាំចូលដែកថយចុះ ៤៤% មកត្រឹម ៩,៩លានដុល្លារ ហើយការនាំចូលក្រណាត់ថយចុះអស់ ៩៩% មកត្រឹម ១,៩លានដុល្លារ ។

នៅត្រីមាសទីបី ២០០៧ ភ្ញៀវមកដល់កម្ពុជា កើនឡើងប្រហែល ១៧% ធៀបនឹងត្រីមាសទីបី ២០០៦ ដល់ ៤៣១,៨១៥នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសកើន ២៤% ដល់ ២៧៨,៥២៣នាក់ ដែលក្នុងនោះអាកាសយានដ្ឋាន ភ្នំពេញទទួលបាន ៤៥% និងអាកាសយានដ្ឋានសៀមរាប ៥៥% ។ ភ្ញៀវមកដល់តាមផ្លូវគោកកើន ៥,២% ដល់ ១៤៤,៥៨២នាក់ វីឯភ្ញៀវមកដល់តាមផ្លូវទឹកថយចុះ ៣,៣% មកត្រឹម ៨៧១០ នាក់។ ខេត្ត

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

សៀមរាប ជាគោលដៅមានប្រជាប្រិយភាពខ្លាំងជាងគេនៅកម្ពុជា ។ នៅត្រីមាសទីបី ខេត្តសៀមរាបទទួលបាន ៤៤% នៃចំនួនភ្ញៀវមកដល់សរុប ។ ភ្ញៀវមកសំរាកលំហែមានចំនួន ៣៩៩,៧៣០នាក់ រឺកើន ១២% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦។ កូរ៉េខាងត្បូងជាប្រទេសនាំមុខគេខាងទេសចរមកធ្វើទស្សនកិច្ចនៅកម្ពុជា ហើយបន្ទាប់មកគឺ ជប៉ុន និង វៀតណាម ។

### អត្រាអតិផរណា និង អត្រាប្តូរប្រាក់បរទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបនៅកម្ពុជា ផ្សព្វផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិសំរាប់ត្រីមាសទីបី កើន ១១,៩% ធៀបនឹងឆ្នាំមុន រឺ ៣,៤% ខ្ពស់ជាងកំណើននៅត្រីមាសមុន ។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិអាកុល កើន ១៦,៩% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ រីឯថ្លៃដឹកជញ្ជូន កើនបន្តិចបន្តួចត្រឹម ២,០% ។

នៅប្រទេសកម្ពុជា ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិអាកុល តំណាងអោយ ៥៨% នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ។ ដូចនេះ ការឡើងថ្លៃម្ហូបអាហារជំរុញអោយមានអតិផរណាជាទូទៅ ។ បន្ថែមលើនេះទៀត ថ្លៃម្ហូបអាហារនៅលើសាកលលោកកើនយ៉ាងលឿន ហើយជះឥទ្ធិពលយ៉ាងខ្លាំងដល់កម្ពុជាដែលជាប្រទេសនាំចូលច្រើន ។ ឧទាហរណ៍ ម្ហូបអាហារនាំចូលពីថៃតំណាងឱ្យ ៦,៦% នៃទំនិញនាំចូលសរុបពីថៃមកកម្ពុជា ។ ដូចនេះ ម្ហូបអាហារនៅថៃដែលឡើងថ្លៃ ៤,៤% បានធ្វើអោយឡើងថ្លៃម្ហូបអាហារដែលកម្ពុជានាំចូលមក។

នៅត្រីមាសទីបី ២០០៧ ប្រាក់រៀលឡើងថ្លៃទល់នឹងប្រាក់ដុល្លារUS ១,៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដោយ ប្តូរបាន ៤០៨២,៣រៀល/ដុល្លារUS ប៉ុន្តែទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ១៨% មកត្រឹម ១៣០,០រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលធ្លាក់ថ្លៃ ១,៦% ដោយប្តូរបាន ២៥,៣ រៀល/១០០ដុង ។

### ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទីបី ២០០៧ រូបិយវត្ថុទូទៅ (M2) សរុប កើន ៥៣% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដល់ ៩៩០៨,២ ពាន់លានរៀល។ រូបិយវត្ថុ (M1) កើន ១២% ដល់ ១៧៤៩,៧ពាន់លានរៀល ក្នុងនេះប្រាក់រៀលចរាចរក្រៅធនាគារ មាន ៩៦% និងប្រាក់បញ្ញើចរន្តមាន ៤% ។ ប្រាក់រៀលកំពុងចរាចរ កើន ១១% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ។ រូបិយវត្ថុផ្សេងៗ ដូចជា ប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស មានចំនួន ៨១៥៨,៥ ពាន់លានរៀល រឺ កើន ៦៧% ។ ក្នុងចំណោមរូបិយវត្ថុផ្សេងៗ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស មានចំនួន ៩៩% រឺកើន ៦៨% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។

កំណើនចំនួនរូបិយវត្ថុទូទៅ (M2) កើតចេញពីដំណើរប្រតិបត្តិការរវាងទ្រព្យសកម្មក្នុងស្រុក និងទ្រព្យសកម្មបរទេស ។ នៅត្រីមាសទីបី ឥណទានក្នុងស្រុក ដែលមានជា ឥណទានដល់រដ្ឋាភិបាលនិងវិស័យឯកជន ប្រាក់បញ្ញើរដ្ឋាភិបាល និងបំណុលផ្សេងៗទៀត កើន ៦០% ដល់ ៣៨២៩,៣ ពាន់លានរៀល ។ ឥណទានផ្តល់ដល់រដ្ឋាភិបាល កើន ១០% ដល់ ២៩៦,៧ ពាន់លានរៀល និងដល់វិស័យឯកជន កើន ៦៣% ដល់ ៥៣៧៦,៤ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាល កើន ៥៩% ដល់ ១៨៤៣,៨ពាន់លានរៀល និងបំណុលផ្សេងៗ កើន ២៧% ដល់ ៣៦៨៩,១ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៤០% ដល់ ៩៧៦៧,៩ពាន់លានរៀល ។

### ស្ថានភាពក្រីក្រ- ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលកររងាយរងគ្រោះ

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលកររងាយរងគ្រោះភាគច្រើន បានកើនឡើង ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។ ផ្ទុយទៅវិញ ប្រាក់ចំណូលរបស់ពលករកាត់ដេរ បានធ្លាក់ចុះ ។

ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុបកើន ៣៧% ដល់ ១៣.០៦០រៀល ដែលជាកំណើនប្រាក់ចំណូលខ្ពស់បំផុតរបស់ពួកគេ ចាប់តាំងពីអង្កេតបានចាប់ផ្តើមនៅឆ្នាំ២០០០ ។ ទោះបីប្រាក់ចំណូលកើនឡើងដូច្នេះក្តី អ្នករត់ម៉ូតូឌុបភាគច្រើនបានត្អូញត្អែរពីបញ្ហាសាំងឡើងថ្លៃ ។ ៨៥% នៃអ្នករត់ម៉ូតូឌុបឆ្លើយសំភាសន៏ មិនមានលទ្ធភាពសន្សំប្រាក់ដើម្បីចាប់យកអាជីពថ្មីទេ ពីព្រោះ ប្រាក់ចំណូលនេះគ្រប់គ្រាន់សំរាប់តែផ្គត់ផ្គង់ជីវភាពគ្រួសារប៉ុណ្ណោះ ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាចគឺ ៨៣០៣រៀល រឺកើន ៣៦% ធៀបនឹងខែវិច្ឆិកា ២០០៦ ។ អ្នកលក់បន្លែតូចតាចនៅភ្នំពេញ ៤៨% ធ្វើចំណាកស្រុកមកពីតំបន់ជនបទ។ ក្នុងចំណោមអ្នកចំណាកស្រុកទាំងនោះ ៩០% បានជួលផ្ទះគេស្នាក់នៅ ដោយត្រូវចំណាយប្រហែល ២០.០០០រៀល/ខែ លើឈ្នួលផ្ទះ ហើយ ១០% ផ្សេងទៀត ស្នាក់នៅជាមួយសាច់ញាតិនៅភ្នំពេញ។

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើន ៤២% ធៀបនឹងឆ្នាំមុន ដល់ ៥៥៦០រៀល ដែលបណ្តាលមកពីការឡើងថ្លៃរបស់អេតចាយ ។ ទោះបីមានកំណើនបែបនេះក្តី ក៏អ្នករើសអេតចាយនៅតែរកមួយថ្ងៃ ហូបមួយថ្ងៃដដែល ។ លើសពីនេះទៀត

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

អ្នកឆ្លើយសំភាសន៏ ចំនួន ៣២% មានជំពាក់បំណុលគេ ដោយសារត្រូវខ្ចីប្រាក់សំរាប់ទិញបាយហូប រឺ ចំណាយព្យាបាលជំងឺ ។

នៅខែវិច្ឆិកា អ្នកធាក់ស៊ីក្លូនៅភ្នំពេញ រកចំណូលបានច្រើនជាងពេលឯទៀតខ្លាំងណាស់ ដោយសារមានមនុស្សកុះករនៅទីក្រុង ដើម្បីចូលរួមពិធីបុណ្យអុំទូក ។ នៅខែនេះ ប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូកើន ២៧% ធៀបនឹងខែវិច្ឆិកា ២០០៦ ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែកើន ៣% ដល់ ៤៧៩០រៀល ។ អ្នកឆ្លើយសំភាសន៏ ៨២% រាយការណ៏ថា ចលនាផ្លាស់ទីរបស់យុវជនក្មេងៗដើម្បីមកធ្វើការនៅតំបន់ទីក្រុង បានធ្វើអោយខ្វះកំលាំងពលកម្មធ្វើស្រែ ដែលនាំអោយឡើងថ្លៃឈ្នួលពលកម្ម ។ ប៉ុន្តែពលករ ៨៥% ត្អូញត្អែរថា នៅតែរកមួយថ្ងៃហូបមួយថ្ងៃដដែល ។

ប្រាក់ចំណូលរបស់អ្នកបំរើតាមភោជនីយដ្ឋានស្រី/ប្រុស នៅថេរធៀបនឹងឆ្នាំមុន។ អ្នកបំរើស្រី/ប្រុសភាគច្រើន ធ្វើចំណាកស្រុកពីខេត្តនានាក្នុងនេះ ៨៥% ស្នាក់នៅជាមួយម្ចាស់ភោជនីយដ្ឋាន ហើយអ្នកនៅសល់គឺជួលផ្ទះគេស្នាក់នៅ ។

នៅខែវិច្ឆិកា ២០០៧ ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញកើនដល់ ១០.៩៥៦រៀល រឺកើន ៧% ធៀបនឹងឆ្នាំ២០០៦ ។ អ្នកឆ្លើយសំភាសន៏ ៩៧% បានរាយការណ៏ថា សកម្មភាពសាងសង់នៅទីក្រុងកើនយ៉ាងខ្លាំង ដែលនាំអោយតំរូវការកម្មករកើនឡើង ។ ប៉ុន្តែផលិតផលនានាឡើងថ្លៃច្រើនជាងកំណើនប្រាក់ចំណូលទៅទៀត ដែលធ្វើអោយកម្មករឆ្លើយសំភាសន៏ ១៣% ត្រូវជំពាក់បំណុលគេ ។

ប្រាក់ចំណូលពិតរបស់កម្មករកាត់ដេរថយចុះ ៨% មកត្រឹម ៨២០៧ រៀល ។ កម្មករឆ្លើយសំភាសន៏ ៦៧% បានរាយការណ៏ថា ការធ្លាក់ចុះនេះបណ្តាលពីម៉ោងធ្វើការថយចុះ ។ កម្មករកាត់ដេរ ២៦% បានប្រាប់ថា បន្ទាប់ពីដោះស្រាយចំណាយលើតំរូវការផ្ទាល់ខ្លួនហើយ ពួកគេមានលុយសល់មួយចំនួនតូចសំរាប់ផ្ញើទៅក្រុមគ្រួសារ ។ កំណើនឧស្សាហកម្មនៅតំបន់ទីក្រុងបានទាក់ទាញប្រជាជនពីតំបន់ជនបទ ពិសេសយុវជនក្មេងៗ ដែលយ៉ាងហោចណាស់ ៩០% នៃកម្មករកាត់ដេរបានធ្វើចំណាកស្រុកពីតំបន់ជនបទ ហើយពួកគេភាគច្រើនមានដីស្រែតិចជាងមួយហិកតា ។

*រៀបរៀងដោយ ផាន់ ដាលីស និងប៉ុន ដូរីណា*


## Cambodia Development Review—2008 Subscription Rates

**Domestic Subscription (Individual)**

☐ English edition ($14) ☐ Khmer edition (5,000 riels) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

☐ English edition ($60 for five copies) ☐ Khmer edition (20,000 riels for five copies) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges). Total payment enclosed..........................................................................

**International Subscription (Individual)**

☐ Thailand, Laos, Vietnam ☐ English edition ($25)* ☐ Khmer edition ($15)*
☐ Asia and Europe ☐ English edition ($30)* ☐ Khmer edition ($20)*
☐ Americas and Africa ☐ English edition ($35)* ☐ Khmer edition ($25)*

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ☐Mr ☐Ms ☐Dr ☐ Other ..........................................................................
First name: .................................... Last name: .................................... Position: ....................................
Organisation / Company: ..........................................................................
Address (CCC Box if applicable): ..........................................................................
City / Province: .................................... Country: ....................................
Telephone: .................................... Fax: ....................................
e-mail: .................................... ☐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តារាងសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## *តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០១-២០០៧*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 | 2.1 | 12.0 |
| ឧស្សាហកម្ម | 105.2 | 67.7 | 137.2 | 187.9 | 914.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 | 51.2 | 187.2 |
| កាត់ដេរ | 26.5 | 27.2 | 68.1 | 132.6 | 174.4 | 30.5 | 9.6 | 23.2 | 26.1 | 36.6 | 24.3 | 40.7 |
| សេវាកម្ម | 118.4 | 145.3 | 168.4 | 91.8 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 | 138.0 | 957.7 |
| សណ្ឋាគារ និងទេសចរណ៍ | 73.8 | 47.1 | 124.1 | 55.9 | 102.6 | 0.0 | 26.2 | 3.5 | 315.3 | 140.3 | 55.0 | 653.8 |
| សរុប | 224.0 | 253.3 | 309.3 | 292.0 | 1096.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 | -61.6 | 504.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -16.8 | 13.1 | 22.1 | -5.6 | 275.6 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 | 91.8 | 334.6 |

*Including expansion project approvals. Source: Cambodian Investment Board*

## *តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០១-២០០៧*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2* | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 14.4 | 22.8 | 21.7 |
| ផ្ទះល្វែង | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 88.9 | 33.2 | 117.5 |
| ផ្សេងៗ | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 35.9 | 88.8 | 40.6 |
| សរុប | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 139.2 | 144.7 | 179.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 78.0 | 3.9 | 24.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 106.5 | 76.0 | 88.2 |

** Revised data. Source: Department of Cadastre and Geography of Phnom Penh municipality*

## *តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០១-២០០៧*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 1268.2 | 1453.2 | 1708.1 | 2108.1 | 2352.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 | 705.0 | 890.8 |
| រួមមាន: សំលៀកបំពាក់ | 1202.2 | 1355.8 | 1628.4 | 2027 | 2253.3 | 568.5 | 632.4 | 782.0 | 716.0 | 677.5 | 688.2 | 846.1 |
| - ទៅសហរដ្ឋអាមេរិក | 840.9 | 943.4 | 1099.8 | 1270.9 | 1546.1 | 402.5 | 438.6 | 522.8 | 483.2 | 499.1 | 451.2 | - |
| - ទៅសហគមន៍អឺរ៉ុប | 323.3 | 356.3 | 414.7 | 590.8 | 503.1 | 110.6 | 142.2 | 188.1 | 160.1 | 106.3 | 163.1 | - |
| - ប្រទេសផ្សេងទៀត | 38.0 | 56.1 | 113.8 | 165.3 | 204.1 | 55.3 | 51.6 | 71.0 | 72.8 | 72.0 | 73.8 | - |
| កសិកម្ម | 66.0 | 97.3 | 79.7 | 81.2 | 99.5 | 34.7 | 20.2 | 25.5 | 20.7 | 30.3 | 16.8 | - |
| - កៅស៊ូ | 25.9 | 29.7 | 35.1 | 38.3 | 36.7 | 7.8 | 9.8 | 13.6 | 10.2 | 8.4 | 6.9 | 11.7 |
| - ឈើ | 22.3 | 16.0 | 10.2 | 11.1 | 10.3 | 2.1 | 2.3 | 2.5 | 1.7 | 2.1 | 2.0 | 0.0 |
| - ត្រី | 6.0 | 4.3 | 2.8 | 10.6 | 10.1 | 1.9 | 1.0 | 1.6 | 1.4 | 0.7 | 0.4 | 1.2 |
| - ផ្សេងៗ | 11.8 | 47.4 | 31.6 | 21.3 | 42.6 | 22.9 | 7.0 | 7.7 | 7.5 | 19.0 | 7.5 | - |
| ការនាំចូលសរុប | 1501.4 | 1707.8 | 1824.9 | 2149.0 | 2513 | 690.7 | 774.9 | 784.3 | 807.1 | 790.9 | 911.6 | 924.5 |
| រួមមាន: ផលិតផលប្រេងកាត | 154.4 | 157.5 | 191.6 | 187.0 | 184.8 | 57.6 | 59.8 | 62.4 | 58.7 | 66.5 | 68.5 | 71.0 |
| - សាំង | - | 25.9 | 33.2 | 30.2 | 40.2 | 10.9 | 12.4 | 13.1 | 13.2 | 15.7 | 20.2 | - |
| - ម៉ាស៊ូត | - | 100.8 | 109.6 | 109.4 | 93.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 | 36.6 | - |
| សំភារៈសំណង់ | - | 12.9 | 80.8 | 95.3 | 134.7 | 37.0 | 39.1 | 42.5 | 35.8 | 44.1 | 31.6* | 34.9 |
| ផ្សេងៗ | - | 1568.2 | 1601.3 | 1914.0 | 2245 | 610.3 | 691.2 | 698.5 | 731.0 | 699.2 | 807.5 | 818.6 |
| ជញ្ជីងពាណិជ្ជកម្ម | -233.2 | -254.6 | -116.8 | -40.9 | -160.1 | -87.5 | -122.4 | 23.2 | -70.4 | -83.1 | -208.1 | -30.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -5.4 | 39.8 | -118.9 | -403.4 | 18.0 | 150.4 | -85.2 |
| ការនាំចេញសរុប | - | - | - | - | - | -6.4 | 8.2 | 23.7 | -8.8 | -3.9 | 0.4 | 26.4 |
| ការនាំចូលសរុប | - | - | - | - | - | -0.03 | 12.2 | 1.2 | 2.9 | -2.0 | 15.3 | 1.4 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 24.9 | 9.2 | -54.1 | -64.9 | 291.4 | 51.1 | -19.5 | -76.2 | 52.0 | -5.0 | 70.0 | -232.3 |
| ការនាំចេញសរុប | 20.1 | 14.6 | 17.5 | 23.4 | 11.6 | 30.3 | 26.7 | 10.6 | 14.3 | 17.3 | 8.0 | 10.3 |
| ការនាំចូលសរុប | 5.9 | 13.7 | 6.9 | 17.8 | 16.9 | 32.6 | 16.2 | 24.0 | 16.8 | 14.5 | 17.6 | 17.9 |

*Import data include tax-exempt imports. * Q2 revision. Sources: Customs and Excise Department, cited by NBC*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០១-២០០៧

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 | 275.6 | 278.5 |
| តាមផ្លូវគោក និងទឹក | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 | 148.9 | 153.3 |
| សរុប | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 | 424.5 | 431.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 | -22.9 | 1.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 | 19.2 | 16.5 |

*Source: Ministry of Tourism.*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០០-២០០៧ (ពាន់លានរៀល)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 595.9 | 731.5 | 732.2 | 1199.6 | 824.9 | 1016.8 |
| ចំណូលចរន្ត | - | 1521 | 1728 | 1733 | 2107 | 2474 | 593.2 | 726.9 | 716.8 | 844.9 | 824.9 | 1012.4 |
| ចំណូលពន្ធ | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 484.7 | 558.6 | 565.8 | 661.8 | 699.9 | 887.7 |
| ពន្ធគយ | 376 | 376 | 424 | 395 | 513 | 573 | 135.5 | 151.7 | 157.2 | 200.0 | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | - | - | - | 487.9 | 642.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | 212.1 | 245.6 |
| ចំណូលមិនមែនពន្ធ | 424 | 424 | 501 | 513 | 530 | 563 | 108.5 | 168.3 | 151.0 | 183.1 | 125.0 | 124.7 |
| អាជីវកម្មព្រៃឈើ | 28 | 29 | 15 | 7 | 2 | 3 | 0.5 | 0.7 | 0.3 | 0.9 | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 124 | 122 | 123 | 120 | 94 | 123 | 11.4 | 30.0 | 11.7 | 30.0 | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | - | - | - | 27.9 | 15.5 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | 88.8 | 93.0 |
| ចំណូលជាមូលធន | 8 | 9 | 16 | 31 | 19 | 152 | 2.7 | 4.6 | 15.4 | 354.7 | 0.0 | 4.5 |
| ចំណាយសរុប | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 932.1 | 1020.1 | 1030.6 | 1191.9 | 923.9 | 1098.7 |
| ចំណាយជាមូលធន | 976 | 977 | 1388 | 1171 | 1163 | 1328 | 390.5 | 394.7 | 423.8 | 429.1 | 367.1 | 408.1 |
| ចំណាយចរន្ត | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 541.7 | 625.4 | 606.9 | 762.8 | 556.8 | 681.6 |
| អប់រំ និងសុខាភិបាល | 344 | 343 | 454 | 473 | 518 | 351 | 80.3 | 202.3 | 150.1 | 281.3 | - | - |
| ការពារជាតិ និងសន្តិសុខជាតិ | 404 | 405 | 438 | 411 | 423 | 451 | 78.1 | 116.7 | 155.3 | 170.1 | - | - |
| ក្រសួងផ្សេងៗទៀត | 636 | 637 | 668 | 702 | 828 | 1165 | 383.2 | 306.4 | 301.5 | 311.4 | - | - |
| បៀវត្សរ៍ | 517 | 509 | 587 | 615 | 640 | 711 | 140.5 | 210.3 | 230.6 | 240.6 | 199.7 | 242.7 |
| ឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | 61.9 | 184.0 |
| សមតុល្យជាទូទៅ | -804 | -802 | -1204 | -993 | -806 | -706 | -336.3 | -288.5 | -298.5 | 7.7 | -99.0 | -81.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 768 | 766 | 1249 | 886 | 864 | 1127 | 308.0 | 341.3 | 335.2 | 376.2 | 344.0 | 313.9 |
| ហិរញ្ញប្បទានក្នុងស្រុក | 36 | 37 | -45 | 106 | 148 | -396 | 28.3 | -52.8 | -36.7 | -383.9 | -245.0 | -213.0 |

*Provisional for 2007. The third quarter data are not yet available. Source: MEF web site*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០១-២០០៧

| (October-December 2006:100) | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | |
| ខេត្ត | - | - | - | - | - | - | - | - | - | 5.9 | 9.0 | 14.4 |
| ភ្នំពេញ | - | - | - | - | - | - | - | - | - | 4.7 | 5.8 | 7.7 |
| កម្ពុជា - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | - | - | 5.7 | 8.5 | 11.9 |
| - មបអាហារ | - | - | - | - | - | - | - | - | - | 8.3 | 12.0 | 16.9 |
| - ដឹកជញ្ជូន | - | -- | - | - | - | - | - | - | - | -3.4 | 1.1 | 2.0 |
| | | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | |
| រៀលគង ១ ដុល្លារ* | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4,094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 |
| រៀលគង ១ បាតថៃ* | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 | 118.0 | 130.0 |
| រៀលក្នុង ១០០ ដុងវៀតណាម* | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 | 24.7 | 25.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 | 79.8 | 80.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1329 | 1521 | 1508 | 2088 | 2633 | 2867 | 3110 | 3333 | 3250 | 3067 | 3100 | 3203 |
| ថ្លៃសាំង (រៀល/លីត្រ) | 2113 | 2084 | 2150 | 2833 | 3442 | 3767 | 4000 | 4200 | 4050 | 3750 | 3900 | 4002 |

Sources: CDRI, NIS and NBC

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០១-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3080 | 3737 | 4027 | 4797 | 5475 | 6410 | 6682 | 6958 | 7224 | 8056 | 9048 | 9768 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 | -172 | 140 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 | -1403 | -1547 |
| ឥណទានដល់ផ្នែកឯកជន | 936 | 1059 | 1337 | 1817 | 2394 | 2,778 | 2997 | 3288 | 3628 | 4066 | 4537 | 5376 |
| រូបិយវត្ថុទូទៅ M2 | 2204 | 2888 | 3329 | 4330 | 5025 | 5711 | 6045 | 6461 | 6942 | 7793 | 8876 | 9908 |
| រូបិយវត្ថុ M1 | 609 | 813 | 937 | 1153 | 1323 | 1449 | 1512 | 1563 | 1658 | 1794 | 1748 | 1750 |
| រូបិយវត្ថុផ្សេងៗ | 1595 | 2075 | 2392 | 3177 | 3702 | 4262 | 4533 | 4898 | 5285 | 5999 | 7128 | 8158 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 | 46.8 | 53.4 |
| រូបិយវត្ថុ M1 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 | 15.7 | 12.0 |
| រូបិយវត្ថុផ្សេងៗ | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 | 66.5 |

Source: National Bank of Cambodia

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

*តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ ( ថ្លៃថេរ ខែវិច្ឆិកា ២០០០)*

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2007 | | |
| | វិច្ឆិកា | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តទៅទំព័រទី ២៤* **ព័ត៌មានថ្មីៗ ពី...**

ពលករ និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត ។ ការសិក្សាស្វែងរកការពិតស្ដីពីវិនិយោគទុនចិននៅកម្ពុជា បានចាប់ផ្ដើមនៅខែកុម្ភៈ ហើយលទ្ធផលដំបូងនឹងទទួលបានក្នុងរយៈពេលមួយឆ្នាំខាងមុខ ។ ការសិក្សាឯកសារស្រាវជ្រាវស្ដីពីពាណិជ្ជកម្ម និងបរិស្ថាន ដែលស្ថិតក្នុងគំរោងមួយមានរយៈពេលមួយឆ្នាំក៏បានបញ្ចប់រួចរាល់ដែរ ។ នៅចុងខែកុម្ភៈ លោក សាំង ច័ន្ទហង្ស បានចូលបំរើការជាអ្នកស្រាវជ្រាវក្នុងផ្នែកនេះ ។

ចាប់ពីដើមឆ្នាំ២០០៨ ផ្នែកសន្ដិសុខមនុស្ស និងការកសាងសន្ដិភាព បានចាប់ផ្ដើមកំនត់វិស័យស្រាវជ្រាវថ្មីរបស់ខ្លួន ។ វិស័យដ៏ល្អមួយ គឺចំណងទាក់ទងជាយថាហេតុរវាងការគំរាមកំហែងដល់មនុស្ស/ភាពក្រីក្រ និងបញ្ហាចោទខាងអភិបាលកិច្ច ការប្រើប្រាស់ធនធានធម្មជាតិ និងសុខមាលភាពសេដ្ឋកិច្ចរបស់បុគ្គលម្នាក់ៗ ។ នៅខែមីនា ផ្នែកនេះបានដាក់សំណើមួយទៅ UNICEF ដើម្បីសិក្សាពីស្ថានភាពយុវជន ហើយទទួលបានកិច្ចព្រមព្រៀងមួយរវាង CDRI និង UNICEF រួចហើយ ។ ផ្នែកនេះក៏កំពុងរង់ចាំកិច្ចព្រមព្រៀងស្រេចបាច់របស់ UNICEF លើគំរោងសិក្សាពីភាពក្រីក្ររបស់កុមារនៅកម្ពុជា ដែលអាចត្រូវការឱ្យ CDRI ធ្វើជាអ្នកអនុវត្តគំរោងជាថ្មីម្ដងទៀត ។ម្យ៉ាងទៀត ផ្នែកសន្ដិសុខមនុស្ស បានកសាងសំណើមួយទាក់ទង នឹងការស្រាវស្រាវលើការបោះឆ្នោត ដើម្បីស្នើដល់អ្នកផ្ដល់ជំនួយមួយចំនួនដែលមានចំណាប់អារម្មណ៍ ដូចជា CIDA, AusAID និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវការគ្រប់គ្រងធនធានទឹក (WRMRCDP) របស់ផ្នែកធនធានធម្មជាតិ និងបរិស្ថាន (NRE) បានបញ្ចប់ដំណាក់កាលសិក្សាទ្រឹស្ដី និងការវាយតំលៃខាងសង្គមនៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ។ NRE បានបង្ហើយសេចក្ដីព្រាងរបាយការណ៍ដំបូងស្ដីពីការវិភាគចំណាយនិងផលចំណេញ នៃការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា ។ មិនតែប៉ុណ្ណោះ NRE កំពុងចុះអង្កេតដល់ទីកន្លែងសំរាប់គំរោងរួមគ្នាមួយស្ដីពីព្រៃត្រូពិកជួយកាត់បន្ថយភាពក្រីក្រ ដែលត្រូវវិភាគលើទិន្នន័យគ្រួសារ និងជាសាកលសំរាប់ ៥ប្រទេសផ្សេងគ្នា ។ NRE ក៏បានធ្វើចប់រួចរាល់នូវអង្កេតបរិស្ថានធម្មជាតិ និងសង្គម ដោយសហការជាដៃគូជាមួយក្រុមការងារមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) សំរាប់ការសិក្សាប្លង់មេនៃការអភិវឌ្ឍវារីអគ្គិសនីនៅកម្ពុជា ។ របាយការណ៍អង្កេតនេះ បានដាក់ជូន JICA រួចហើយ ។ នៅថ្ងៃ២៤-២៨ មីនា NRE បានរៀបចំវគ្គបណ្ដុះបណ្ដាលមួយ ស្ដីពីសេដ្ឋកិច្ចបរិស្ថាននៅ CDRI ដែលបានទទួលជំនួយឧបត្ថម្ភពីកម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចនៅអាស៊ីអគ្នេយ៍ (EEPSEA) និងមានអ្នកចូលរួមមកពី ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសាកលវិទ្យាល័យរដ្ឋ និង ឯកជននានា ។

ផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ កំពុងបន្ដសិក្សាពីចលនានៃភាពក្រីក្រ ។ អង្កេតមូលដ្ឋានស្ដីពីផលិតផលកសិកម្ម និងជំនួញ ដែលជាផ្នែកមួយនៃគំរោងស្រាវជ្រាវរបស់បណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) បានចប់រួចរាល់នៅដើមឆ្នាំ២០០៨ ហើយការងារវិភាគលទ្ធផល និងសរសេររបាយការណ៍ កំពុងដំណើរការទៅមុខ ។ ផ្នែកនេះ គឺជាអ្នកអនុវត្តមួយក្រុមនៅក្នុងគំរោងកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប ដែលផ្ដល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ដៃគូផ្សេងៗទៀតក្នុងគំរោងនេះគឺមាន វិទ្យាស្ថាន សិក្សាពីការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM-LI) និង ក្រុមប្រឹក្សាសំរាប់ការអភិវឌ្ឍកសិកម្ម និងជនបទ (CARD) ។ គំរោង នេះចាប់ផ្ដើមនៅខែកុម្ភៈ ដោយមានរយៈពេលបំផុសគំនិត ៦ខែ ដែលក្នុងនោះ ស្ថាប័នអនុវត្តគំរោងទាំងអស់ ជាពិសេស CDRI និង CBNRM-LI ត្រូវកសាងផែនការការងារលំអិតសំរាប់គំរោងទាំងមូល ដូចជា គំរោងថវិកា ការវាយតំលៃពីតំរូវការបណ្ដុះបណ្ដាល ព្រមទាំងកំណត់ប្រធានបទត្រូវសិក្សា និងតាក់តែងវិធីសាស្ដ្រសំរាប់ធ្វើអង្កេតមូលដ្ឋាន ។ វិទ្យាស្ថាន CDRI បានចុះហត្ថលេខា លើឯកសារកិច្ចព្រមព្រៀងគ្រប់គ្រងជាដៃគូមួយ សំរាប់ការគ្រប់គ្រងគំរោងស្វែងយល់ពីលំហូរសត្វចិញ្ចឹម និងគ្រោះថ្នាក់នៃការចំលង ជំងឺសត្វឆ្លងកាត់ព្រំដែនដែលទទួលថវិកាពី មជ្ឈមណ្ឌលអូស្ដ្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ។ សកម្មភាពស្រាវជ្រាវជាក់លាក់នានាសំរាប់គំរោងនេះ នឹងត្រូវកំណត់ ហើយព្រមព្រៀងគ្នាដោយភាគីទាំងពីរនៅក្នុងអំឡុងពេលដំណើរការគំរោង ។

# ព័ត៌មានថ្មីៗ ពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងកិច្ចសហការជាមួយធនាគារ ANZ Royal បានរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី២ នាថ្ងៃទី២៨ កុម្ភៈ ២០០៨ នៅរាជធានីភ្នំពេញ ដោយបានអញ្ជើញថ្នាក់ដឹកនាំស្ថាប័នរដ្ឋាភិបាល ស្ថាប័នឯកជន ស្ថាប័នសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍នានា មកចូលរួមពិភាក្សាផ្លាស់ប្ដូរយោបល់លើបញ្ហាចម្បងៗក្រោមប្រធានបទរួម "ការកៀងគរធនធានកម្ពុជា: ធនធានមនុស្ស ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ ដើម្បីការអភិវឌ្ឍប្រកបដោយគុណភាព កំណើនសេដ្ឋកិច្ច និងវិបុលភាព" ។ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់សុន្ទរកថាគន្លឹះទាក់ទងនឹងប្រធានបទសន្និសីទ ។ បន្ទាប់មក អ្នកចូលរួមទាំងអស់បានចូលរួមពិភាក្សាជា ៥ វគ្គធំៗ:

- ប្រទេសកម្ពុជា: ការពិនិត្យពីស្ថានភាពម៉ាក្រូនៅឆ្នាំ២០០៨-សូចនាករសំខាន់ៗ បញ្ហាប្រឈមខាងអភិវឌ្ឍន៍ តំបន់យើង វិស័យឯកជន
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា - ព្រៃឈើ ជលផល និងរ៉ែ
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា - ដីធ្លី អចលនទ្រព្យ ការប្រើប្រាស់ដីប្រកបដោយផលិតភាព និងការអភិវឌ្ឍ
- ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានមនុស្សប្រទេសកម្ពុជា
- ប្រទេសកម្ពុជាឆ្នាំ២០០៨ និងទៅអនាគត: ភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ ជាកំលាំងជំរុញការអភិវឌ្ឍ ការរីកលូតលាស់ និងវិបុលភាព

## ផ្នែកស្រាវជ្រាវ

នៅអំឡុងដើមឆ្នាំ២០០៨ គំរោងជាច្រើនដែលចាប់ផ្ដើមអនុវត្តនៅចុងឆ្នាំ២០០៧ បានឈានដល់ដំណាក់កាលចុះស្រាវជ្រាវដល់ទីកន្លែង ។ ក្នុងពេលជាមួយគ្នា CDRI បានចាប់ផ្ដើមគំរោងសិក្សាថ្មីៗជាច្រើន ដែលគំរោងខ្លះធ្វើឡើងដោយផ្នែកតែមួយ ហើយគំរោងខ្លះទៀតត្រូវអនុវត្តដោយផ្នែកជាច្រើនរួមគ្នា ។ នៅខែមករា ផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់សាធារណៈ (DGPSR) បានសហការជាមួយផ្នែកធនធានធម្មជាតិ និងបរិស្ថាន (NRE) ធ្វើការស្រាវជ្រាវសាកល្បងមួយនៅខេត្តក្រចេះ និងចាប់ផ្ដើមចុះស្រាវស្រាវសំរាប់ការសិក្សាទាំងពីរ លើការដឹកនាំនយោបាយក្នុងមូលដ្ឋាន និងលើអភិបាលកិច្ចធនធានរួមដោយផ្ដោតលើករណីធនធានទឹក ។ ផ្នែក DGPSR បានបង្ហើយឯកសារពិភាក្សាចំនួនពីរដែលបានមកពីការសិក្សាលើគណនេយ្យភាពនៃអភិបាលកិច្ចតាមខេត្ត រីឯឯកសារទីបី កំពុងរង់ចាំយោបល់ពីអ្នកជួយពិនិត្យខ្លឹមសារទូទៅ ។ នៅដើមខែមីនា ផ្នែកនេះបានធ្វើបទបង្ហាញនៅវេទិកាសាធារណៈ ដូចជា ការឈានទៅរកភាពជាអ្នកដឹកនាំរបស់ស្ត្រី ដែលរៀបចំឡើងដោយគណៈកម្មាធិការលើកកំពស់ស្ត្រីក្នុងកិច្ចការនយោបាយ និងកិច្ចប្រជុំរាយការណ៍ជូនគណៈកម្មការ ព្រឹទ្ធសភា និងរដ្ឋសភាជាតិ ។ អ្នកស្រាវជ្រាវពីរនាក់ បានចូលបំរើការ ក្នុងផ្នែកនេះគឺ លោក អ៊ូ ស៊ីវហួច ជានិស្សិតបញ្ចប់ការសិក្សាពីសាកល វិទ្យាល័យ Waseda និងកញ្ញា ជាជូ ជានិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរដ្ឋ Michigan ។

នៅថ្ងៃទី១៩ កុម្ភៈ ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ បានធ្វើបទបង្ហាញលើសេចក្តីព្រាងរបាយការណ៍មួយស្ដីពីស្ថាប័នពាក់ព័ន្ធក្របខ័ណ្ឌច្បាប់ និងគោលនយោបាយគ្រប់គ្រងចំណាកស្រុកពលករជូនដល់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បណ្ដាទីភ្នាក់ងារជ្រើសរើស

*តទៅទំព័រទី ២៣*


ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១២ លេខ ១ ខែមករា-មីនា ឆ្នាំ២០០៨

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។



**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh



គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ

កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង គីម ចិត្រា

ជំនួយការកែសំរួល: យេន សុផានី

រោងពុម្ពដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព CDRI



© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។


ISSN 1560-7615 / ISBN 978-99950-52-06-5


ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។